# ការប្រឈមមុខនៃចេរភាពទីផ្សារ:

## គណ្យនីយភាព និងការផ្លាស់ប្តូរការគ្រប់គ្រងកម្មខធីកសិកម្ម និងការផ្តល់អំណាចរបស់អង្គការសេដាក នៅប្រទេសកម្ពុជា


រៀបរាងដោយ:

ហាត ហួយយ័រ

សកលវិទ្យាល័យ អកស្វើត


បកប្រែដោយ : សោម ពិសិដ្ឋ

មេសា 2008

## សេចក្តីថ្លែងអំណរគុណ

និក្ខបទនេះអាចកើតឡើងបានដោយសារមានការយកចិត្តទុកដាក់ ការគាំទ្រនិងមតិរិះគុណក្នុងន័យស្ថាបនាពីមជ្ឈដ្ឋានមនុស្សជាច្រើននៅក្នុងប្រទេស កម្ពុជា និងនៅប្រទេសអង់គ្លេស។ ខ្ញុំសូមអគុណជាអនេកទៅកាន់អ្នកផ្តល់ប្រឹក្សារបស់ខ្ញុំ Graham Brown ក្នុងការជួយកែលំអនូវកំ ហុសឆ្គង ហើយចំពោះលោក សោម ពិសិដ្ឋ ដែលជាជំនួយការ ជាអ្នកផ្តល់ពត៌មាន នឹងជាមិត្តដ៏ល្អ។ នៅក្នុងប្រទេសកម្ពុជាខ្ញុំត្រូវបាន យកចិត្តទុកដាក់ដោយចិត្តសប្បុរស និង ដោយ សមាន ចិត្តល្អបំផុតពីបុគ្គលិកអង្គការ សេដាក រួមមានលោក បាវ វុទ្ធី លោក យ៉ង សាំង កុមា លោក យី គឹមថាន និង លោក អយ ធី។ សូមដឹងគុណលោក យ៉ង សាំកុមា និង លោក សួន សេង ដែលបានជួយរំលឹកនិងពិនិត្យរាល់កំហុសឆ្គងនានា ដែលមានក្នុងសេចក្តីព្រាងនៃនិក្ខេបទ នេះ។ អគុណចំពោះ បងស្រី សុខា បងប្រុសលក្ខ័ និងពូមុំ ដែលបានផ្តល់កន្លែង ស្នាក់នៅដ៏កក់ក្តៅនៅ ភូមិ អង្គតាសោម និងភូមិ វះពោះ។ សំរាប់ការធ្វើអោយខ្ញុំនឹកឃើញឡើងវិញនូវជីវិតរស់នៅរបស់ប្រជាជនកម្ពុជា និងមិត្តដ៏កក់ក្តៅ ព្រមទាំងការជួយបកប្រែនិក្ខបទនេះ អគុណអស់ពីបេះដូងជូនចំពោះសំលាញ់ សេង សារី និងភរិយារបស់គាត់ មាស ពិសី ។ អគុណជាសិសេសចំពោះសំលាញ់ទាំងពីរនាក់គឺ Ayako Hiwasa និង Payal Rajpal ដែលផ្តល់នូវទស្សន និង ការរួមដំណើរដោយមិនគិតពីការនឿយហត់នៅកម្ពុជា។ សំរាប់ការជួយរៀបចំការងារនៅទីក្រុងភ្នំពេញខ្ញុំសូមអគុណចំពោះបុគ្គលិករបស់មជ្ឈមណ្ឌលខេមរសិក្សា ជាពិសេសលោក ខេងពិទូកេត្យា Philippe Peycam និងអ្នកថែទាំមជ្ឈមណ្ឌលដែលខ្ញុំស្គាល់។ ជាចុងក្រោយនៅកម្ពុជាខ្ញុំសូមផ្តល់នូវសេចក្តីដឹងគុនរបស់ខ្ញុំ ចំពោះបុគ្គលិកអង្គការសេដាកនៅតំបន់២ដែលបានរីករាយនូវវត្តមាននិងបានឆ្លើយសំនួរដ៏ពិបាកៗរបស់ខ្ញុំ។នៅប្រទេសអង់គ្លេស ខ្ញុំសូមជូន នូវការ ដឹងគុណរបស់ខ្ញុំចំពោះលោក Julie Taylor ដែលបានជួយពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រៀង ដ៏ច្របូកច្របល់របស់ខ្ញុំនេះហើយនឹងអគុណចំពោះការពិនិត្យជាចុងក្រោយរបស់គ្រួសារខ្ញុំនៅសហរដ្ឋអាមេរិក។

## ១.០ សេចក្តីផ្តើម

និក្ខេបទនេះបង្ហាញអោយឃើញថាតើ ហេតុដូចម្តេច និងហេតុអ្វី កម្មវិធីកសិកម្មសមស្របរីកសាយទៅហួសពីព្រំដែននៃនិរន្តរភាពបរិស្ថាន ហើយបានបង្កើតនូវការ សំរបសំរួលជាមួយប្រពន្ធ័ពួកមូលធនពិភពលោក។ក្នុងដំណើរការអភិវឌ្ឍន៍ បញ្ញាត្តិនៃនិរន្តរភាពបានអភិវឌ្ឍន៍ឡើងដោយរួមបញ្ចូលនូវគំនិតនិងការអនុវត្តន៍ដ៏ទូលំទូ លាយមួយដោយចាប់ផ្តើមពីវិធីសាស្រ្តជាក់លាក់សំរាប់ធ្វើអោយរីកចំរើនប្រសិទ្ធភាព បរិស្ថាន ដើម្បីពង្រីកនូវទ្រឹស្តីទាក់ទងនិងការចងសម្ពន្ធ័សង្គមអ្នកប្រើប្រាស់ឡើងវិញ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែងនិរន្តរភាពត្រូវចូលរួមដោយអ្នកប្រើប្រាស់ម្នាក់ៗតាមទំលាប់របស់ពួកគេ។ ក្នុងរយៈពេលខ្លីអ្នកធ្វើការអភិវឌ្ឍន៍ជានិច្ចកាលបានអោយនិយមន័យនៃនិរន្តរភាពជាសាមញ្ញថា ជាការការពារជាមុនក្នុងសកម្មភាពបរិស្ថានដូចជាការលើកទឹកចិត្តចំពោះផលិតផលស្រូវធម្មជាតិ។គោលដៅដ៏សាមញ្ញនេះជានិច្ចកាលប្រែទៅជាជោគជ័យនិងធ្វើអោយអ្នកធ្វើការអភិវឌ្ឍន៍ហ៊ានសំដែងចេញសកម្មភាពទាំងនេះនឹងនៅស្ថិតស្ថេរហួតអ្នកធ្វើការអភិវឌ្ឍន៍ទទួលស្គាល់ថាបច្ចេកទេសកសិកម្មជាព្រំដែននៃត្រូវការប្រើប្រាស់ទោះបីជាទំហំទីផ្សារ និង រូបសណ្ឋានសង្គមត្រូវបាននាំយកទៅក្នុងការកំរៃតំរង់ជាមួយផលិតផលពិតៗក៏ដោយ។ដូច្នេះគំនិតផ្តួចផ្តើម តំបូងក្នុងបញ្ហារយៈពេលខ្លី ជាយថាហេតុនឹងធ្វើអោយមានបញ្ហារយៈពេលវែងនិងញែកអោយឃើញទិដ្ឋភាពខុសគ្នាថែមទៀត។ វាច្បាស់ណាស់ថាផ្លូវដ៏វែងដើម្បីឆ្ពោះទៅដល់លទ្ធផលចានិរន្តភាព (ឧ:និរន្តភាពនៃសង្គមអ្នកប្រើប្រាស់ និរន្តភាពនៃឧស្សាហកម្មនិងកសិកម្មសមស្រប។ល។) ទាក់ទងយ៉ាងទូលំទូលាយទៅនឹងសង្គម និងទីផ្សារ។ នៅក្នុងនិក្ខបទនេះខ្ញុំពិនិត្យថាតើគោលបំនងនៃការអភិវឌ្ឍន៍ជនបទដែលមានឥទ្ធិពលទៅលើស្ថានភាពបត់បែនរបស់គំនិតនិងការអនុវត្តន៍ដោយវិភាគ ទៅលើកម្មវិធីពីអតីតកាលនិងអនាគតកាលរបស់មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(សេដាក)[1]។ ច្បាស់ជាងនេះទៅទៀតខ្ញុំនឹងបកស្រាយសំណួរ ថាតើផលវិបាក សំរាប់ប្រជាជនជនបទក្នុងការបន្តអោយនិយមន័យនិរន្តរភាពក្នុងផ្លូវដែលអនុគ្រោះចំពោះក្របខណ្ឌទីផ្សារ រឺ ទេ?

ខ្ញុំនិងលើកយកគោលសំខាន់នៃគុណវិបត្តិនិងគុណសម្បត្តិទាក់ទងនឹងគំរូ អង្គការក្រៅរដ្ឋាភិបាលដែលទទួលខុសត្រូវនៃសហគ្រាសសង្គមដែលទទួលយកដោយ អង្គការសេដាកនាពេលកន្លងមក។ជាពិសេសខ្ញុំបង្ហាញការផ្តោតអារម្មណ៍ជាតំបូងបំផុតទៅលើការធ្វើអោយប្រសើរនូវកំរិតជីវភាពកសិករដែលពឹងផ្អែកទៅលើកសិកម្មដំណាំស្រូវដែលប្តូ

[1] ជាអក្សរកាត់របស់បារាំង Centre d’Étude et de Développement Agricole Cambodgien

រទៅថាការចាំបាច់សំរាប់រៀបចំនូវបណ្តាញទីផ្សារដើម្បីពង្រីកនូវសមត្ថភាពគ្រប់គ្រង។ ដោយសារតែបណ្តាញទាំងនេះត្រូវបានអោយនិយមន័យដោយ អង្គការសេដាក ត្រូវបានធ្វើជានិរន្តភាព ការរីកចំរើននៃសមត្ថភាពរបស់ពួកគេគឺត្រូវបានមើលឃើញយ៉ាងជាក់ច្បាស់ពីការអភិវឌ្ឍន៍ជានិរន្តភាព។ ការបង្កើនកំរិតជីវភាពនៅជនបទបានក្លាយជាការរីកសាយនៃប្រព័ន្ធផលិតផល។ នេះត្រូវបានគេកត់សម្គាល់ដោយការផ្លាស់ប្តូរគនេយ្យភាពដែលធ្វើដោយប្រយោល មធ្យោបាយនៃការជំរុញសេចក្តីត្រូវការលើទីផ្សារសំរាប់គូសវាសចំពោះកសិករដែលមិនទាន់មានគំនិតផ្តួចផ្តើម ជាជាងការធ្វើដោយប្រយោលនូវវិធីសាស្ត្រសហគមន៍ដោយចាប់ផ្តើមកម្មវិធីអភិវឌ្ឍន៍សហគមន៍។ ខ្ញុំវែកញែកថាការផ្លាស់ប្តូរនេះគឺជាសញ្ញាណនៃគំនិតដ៏ទូលំទូលាយក្នុងការផ្តួចផ្តើមកម្មវិធីកសិកម្មសមស្របដោយពឹងផ្អែកលើអ្នកធ្វើកំនែទំរង់ អ្នកបច្ចេកទេស និងការបង្កើននូវការត្រួតត្រា និរន្តរភាពទីផ្សារនៃការអភិវឌ្ឍន៍ដោយចេរភាព (SustainAbility, 2003) ។ កិច្ចការងារនោះបានផ្តល់នូវសក្តានុពលដ៏មហិមារសំរាប់ជំនួសនូវទំរង់ឧស្សាហកម្មបែបបុរាណក្នុងការអភិវឌ្ឍន៍កសិកម ប៉ុន្តែវាក៏បង្កើននូវភាពងាយរងគ្រោះកាន់តែច្រើនឡើងដោយគំនិតរបស់ពួកគេ (Jacobs, 1999: 281)។

## ២.០ កំរិតជីវភាពរបស់សហគមន៍ស្រមោល: ទ្រឹស្តីសមស្របនៃនិរន្តរភាព និងការអភិវឌ្ឍន៍ជនបទ

ការសិក្សានេះផ្តោតទៅលើទំនាក់ទំនងនៃប្រធានបទ២ផ្សេងៗពីគ្នាគឺ : ក្រុមគ្រួសាររបស់កសិករនិងស្ថាប័នផ្សេងៗ ហើយថាតើ ពួកគេចងសម្ព័ន្ធជាមួយគ្នាក្នុងបណ្តុំច្រវ៉ាក់ទំនាក់ទំនងនៃអន្តរអំពើទ្រង់ទ្រាយតូចនិងធំដែលបង្កើតឡើងនូវតំណាងពិសេសមួយរបស់សង្គមធំ ដែលជាទីកន្លែងនៃការអភិវឌ្ឍន៍សមស្រប (Knorr-Cetina, 1981)។ ជាពិសេសខ្ញុំផ្តោតថាតើចំនេះដឹងនៃបច្ចេកវិទ្យាផ្សេងៗដូចជា: ប្រពន្ធ័ប្រពលវប្បកម្មស្រូវ (បវស) ការបង្កើតក្រុមនិងសហគ្រាសសង្គម ដែលធ្វើឲ្យកើតឡើងនូវការងារដោយ **សេដាក** ដើម្បីបញ្ចូលកសិករក្នុងការចូលរួមសិក្សា ការអនុវត្តន៍គំរូ នៃការអភិវឌ្ឍន៍សមស្រប។ អ្នកផ្តល់ពត៌មានរបស់ខ្ញុំរួមមានកសិករចំនួន៧០គ្រួសារក្នុងស្រុកចំនួន៣ដែល **សេដាក** បានធ្វើការជាមួយនៅក្នុងខេត្តតាកែវ ព្រមទាំងការសំភាសន៍ជាង ៤០នាក់ជាមួយកសិករ មន្ត្រីរដ្ឋាភិបាល និង បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល។និក្ខបទនេះបានវិភាគទៅលើស្ថាប័ន

សង្គមសេដ្ឋកិច្ចផ្សេងៗដែលបង្ហាញដោយបណ្តាញអ្នកទ្រឹស្តីដើម្បីពន្យល់បកស្រាយពីតំណើការនៃការចូលរួមនឹងការពង្រីកបណ្តាញ។

## ២.១ ការបញ្ចូលការអនុវត្តន៍នៃនិរន្តរភាពនិងការអភិវឌ្ឍន៍វិស័យកសិកម្ម

នៅពេលបច្ចុប្បន្ន និរន្តរភាពក្នុងវិស័យកសិកម្មគឺមានទំនោរយ៉ាងធំពីលោកខាងជើង ជាពិសេសមានឥទ្ធិពលមកពីពួកបរិស្ថាននិយមនិងពួកឧស្សាហកម្មទំនើបនិយម ហើយបន្ទាប់មានឥទ្ធិពលពីពួកសេដ្ឋកិច្ចសេរី(Adams,1990)។ គំរូនិរន្តរភាពដំបូងគឺមានលក្ខណៈសាមញ្ញ និងទូលំទូលាយលេចឡើងពីពួកឧស្សាហកម្មទំនើបនិយមក្នុងការវិលត្រលប់ទៅរកផលិតកម្មបែបបុរាណ នាំមុខដោយអ្នករស់នៅបែបសាមញ្ញ និងកេរឈ្មោះកសិដ្ឋានជនបទ (Leopold, 1981; White, 1967; Wilson, 1996)។ ការបកស្រាយជាលក្ខណៈនៃសកម្មជនមួយចំនួនដូចជា សកម្មជនសិទ្ធិសត្វ ក្រុមគ្រួសារកសិករ និងសិប្បករជនបទ ការរើសអើងរបស់អ្នកប្រើប្រាស់ និងក្តីបារម្ភរបស់ពួកក្សេត្រសាស្ត្របានបង្កើនឡើងយ៉ាងឆាប់រហ័សនូវការយល់ដឹងអំពីបរិស្ថាននឹងការចូលរួមគាំទ្រដើម្បីសុខភាពអន្តរជាតិ នឹងសន្ធិសញ្ញាបរិស្ថាន (Singer, 1974)។ បច្ចុប្បន្នថ្មីៗនេះគំរូនេះបានកើតឡើងនិងប្រឈមមុខបញ្ហាសេដ្ឋកកិច្ច រឺភាពប្រាកដនិយមលើទស្សនៈវិស័យនៃបរិស្ថាននិងការអភិវឌ្ឍន៍សង្គម (Freeman, 1998)។ និយមន័យថ្មីនេះមិនត្រឹមតែមានលក្ខណៈបត់បែនឆ្ងាយពីក្តីបារម្ភតិចតួចនៃលំហូសេដ្ឋកិច្ច នឹង ទំនើបនីយកម្ម (Friberg & Hettne, 1985) រឺក៏ដូចជាការធ្លាក់ក្នុងផ្លូវជាមួយការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចបែបសេរី ពីព្រោះវាចែករំលែកនូវមូលដ្ឋានគ្រិះប្រហាក់ប្រហែលគ្នា នូវការកើនឡើងមូលធន ការប្រកួតប្រជែង និង ប្រសិទ្ធភាព (Adams, 1995; Aseniero, 1985; Haque, 1999)។ រវាងការបែងចែកនៃការអនុវត្តន៍នៃការអភិវឌ្ឍន៍ដោយចិរភាពនេះ គំរូនៃការអភិវឌ្ឍន៍ថ្មីៗជាច្រើនបានលេចឡើង។ ការប្រកួតប្រជែងដោយស្មើភាពក្នុងវិស័យពាណិជ្ជកម្មគឺជាការបង្ហាញឲ្យឃើញនូវប្រព័ន្ធជាច្រើន នូវវិធីសាស្ត្រសេដ្ឋកិច្ច ដើម្បីពាក់ព័ន្ធជាមួយនឹងជីវភាពកសិករជនបទដោយឆ្លងកាត់និយាមនៃនិរន្តរភាព។សេចក្តីថ្លែង ការណ៍របស់ស្ថាប័នពិភពលោកបានបំបោងនូវទំនោរថ្មីនេះ និងសំភារៈនីយកម្មនៅក្នុងសន្ធិសញ្ញា ធ្វើឲ្យកើតមាននូវការរៀបចំយន្តការអភិវឌ្ឍន៍ស្អាតក្រុងក្យូតូ។ ចំពោះស្ថាប័នដែលមិនបានទទួលផលចំនេញក៏បានលើកទឹកចិត្តឲ្យទទួលយកផែនការជំនួញ និង រចនាសំព័ន្ធទីផ្សារ(SustainAbility, 2003)។

*មជ្ឈមណ្ឌលសិក្សាអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក)*

សេដាកជាអង្គការក្រៅរដ្ឋាភិបាលកំរិតជាតិមួយក្នុងការដំណើរការនៃការកំនត់ន័យរបស់ខ្លួនឡើងវិញ នឹងការអនុវត្តន៍ជាប្រព័ន្ធក្នុងការឆ្លើយតបទៅនឹងទស្សនៈដែលកម្មវិធីតំបូងរបស់ពួកគេបានកំនត់នូវព្រំដែនដោយសក្តានុពលរបស់ពួកគេទៅលើការលេចឡើងនូវការប្រឈមមុខក្នុងការអភិវឌ្ឍន៍។ សេដាក បង្កើតឡើងនៅឆ្នាំ ១៩៩៧ដោយជំនាញការជនជាតិកម្ពុជាចំនួន ៧ រូប ដោយផ្តោតលើការលើកទឹកចិត្តទៅលើការគ្មានឥទ្ធិពលពីខាងក្រៅ ការរៀបចំការគ្រប់គ្រង ការរីកចំរើននៃវិស័យកសិកម្ម **សេដាក** បានថ្លឹងថ្លែងពីផលប្រយោជន៍ដែលបានមកពីការលូតលាស់នៃចលនាអភិវឌ្ឍឧស្សាហកម្មជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិផ្សេងៗទៀត។ អង្គការក្រៅរដ្ឋាភិបាលរបស់បារាំងមួយឈ្មោះGRET[2]បានផ្តល់ជំនួយជាលើកតំបូងដល់សកម្មភាពរបស់ **សេដាក** ដោយបានផ្តល់ជាពូជសំរាប់ស្វែងរកជំនួយនានាដែលសមស្របនឹងការអភិវឌ្ឍន៍កម្មវិធីផ្តួចផ្តើមជនបទរបស់ពួកគេ។ ការទទួលស្គាល់កម្មវិធីនេះហើយនឹងកម្មវិធីជាមូលដ្ឋានបានទាក់ទាញជំនួយពី Oxfam America និងឆ្នាំក្រោយៗទៀតទទួលបានជំនួយពីអ្នកផ្តល់ផ្សេងៗជាច្រើន។ ការចាប់ផ្តើមតំបូងរបស់ **សេដាក** ក្នុងអំឡុងពេលដ៏ឆាប់រហ័សនេះគឺជាជោគជ័យក្នុងការធ្វើឲ្យការដាំដុះស្រូវបែបធម្មជាតិ ការអនុវត្តន៍កសិកម្មដ៏ទៃទៀតបានរីកឡើង។ អត្តសញ្ញាណឬ គោលបំណងតំបូងរបស់ **សេដាក** បានបង្ហាញយ៉ាងច្បាស់ថាវាត្រូវបានជំរុញនឹងលើកទឹកចិត្តឲ្យការអនុវត្តន៍កសិកម្មត្រូវបានបញ្ចូលទៅក្នុងការអនុវត្តន៍នៃកសិកម្មសមស្រប ហើយ ការងាររបស់ពួកគេបានទាក់ទាញផងដែរនូវគំរោងពីពួកទំនើបនិយម AusAID នៃវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ ដែលហៅថា វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)[3]។ កាបូកបន្ថែមជាបន្តបន្ទាប់នូវហេតុផលនៃការអភិវឌ្ឍន៍ដោយចេរភាព **សេដាក** បានចាប់ផ្តើមពង្រីកទំហំកម្មវិធីផ្សេងៗយ៉ាងឆាប់រហ័ស។ វាបានចាប់ផ្តើមលើកទឹកចិត្តឲ្យបង្កើតសមាគមន៍កសិករក្នុងគោលបំណងធ្វើឲ្យស្ថិតនៅក្រោមចំណាប់អារម្មណ៍របស់ក្រុមនានាដែលអាចបង្កើតបានដោយឆ្លងកាត់ពត៌មាននឹងកម្មវិធីរបស់**សេដាក** ដែលត្រូវបានផ្សព្វផ្សាយ។ សមាគមន៍កសិករទាំងនេះត្រូវបានត្រួតពិនិត្យដោយ **សេដាក** ជាចំណុចចាប់ផ្តើមការជំរុញកម្មវិធីផ្តល់អំណាច និង ការរីកដុះដាលនៃវេទិការបស់កសិកររួមជាមួយការសហការគ្នានៅក្នុងមូលដ្ឋាន[4]។ ជាសំខាន់សមាគមន៍កសិករ

[2] GRET ជា the Group for Research and Exchange of Technology.

[3] (Yi, 21 September 2007)

[4] (Yi, 21 September 2007)

នេះក៏ជាផ្នែកនៃការគ្រប់គ្រងសំរាប់ក្រុមសន្សំនៅក្នុងមូលដ្ឋានដែលផ្តល់នូវការប្រាក់ខ្ពស់សំរាប់អ្នកផ្តល់ឥណទានឲ្យគេខ្ចីនឹងជាអង្គការមីក្រូហិរញ្ញវត្ថុដ៏ធំ។ បន្ទាប់មកទៀតសមាគមន៍កសិករអាចមានលទ្ធភាពជ្រើសរើសកសិករអោយចូលរួមក្នុងកម្មវិធីទីផ្សារផលិតផលកសិកម្មធម្មជាតិរបស់ **សេដាក** ដែលបានផ្តល់នូវជំនួយការខាងទីផ្សារសំរាប់ការឃោសនាផលិតផល កសិកម្មធម្មជាតិ។ ការលូតលាស់នៅឆ្នាំបន្តបន្ទាប់របស់ស្ថាប័ននានាកើនឡើងយ៉ាងឆាប់ រហ័សនៅក្រោមលក្ខខណ្ឌទាំងនេះ។ **សេដាក** បានបង្ហាញជាឈុតៗឲ្យឃើញនៅក្នុងពិធីរំលឹកខួប ១០ ឆ្នាំ នៅទីក្រុងភ្នំពេញនាថ្ងៃទី ១ ខែសីហា ២០០៧ ដែលជាតំណើការឆ្ពោះទៅរកវិធីសាស្ត្រនៃការរៀបចំទីផ្សារដើម្បីលើកទឹកចិត្តកសិកម្មសមស្រប[5]។

បន្ទាប់ពីពិធីរំលឹកខួប ១០ ឆ្នាំភ្លាមការប្រជុំធំៗត្រូវបានធ្វើឡើងដើម្បីប្រាប់តំ ណឹងទាក់ទងនឹងការសម្រេចចិត្ត និងផ្តួចផ្តើមត្រូវបានគេហៅជាលើកតំបូងថា (គំរោងការធ្វើជំនួញ)គំរោងនេះ **សេដាក** បានសង្ឃឹមថានឹងអាចបង្ហាញពីវប្បធម៌ ការរៀបចំមានលក្ខណៈជាស្ថាប័ន និង ចៀសវាងនូវឧបសគ្គក្នុងការជំរុញលើកទឹកចិត្តលើទីផ្សារ សំរាប់ផលិតផលកសិកម្មសមស្រប។នៅឆ្នាំ ២០០៨ **សេដាក** បានបែងចែកជាបីកម្មវិធីសំខាន់ៗគឺ **១** ការអភិវឌ្ឍន៍កសិកម្មនិងសង្គម **២** ជាកសិកម្មដែលពឹងផ្អែក លើសហគ្រាស **៣** ស្ថាបប័នសេដាកក្នុងការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន (សេដាក កុម្ភៈ ២០០៨)។ កម្មវិធីទី១អាចមើលឃើញថាជាកម្មវិធីដើមតំបូងរបស់ **សេដាក** ដែលផ្តោតលើការរីករាលដាលនៃប្រព័ន្ធប្រពលវប្បកម្មស្រូវ(បរស) ការចិញ្ចឹមសត្វតាមគោលការណ៍ធម្មជាតិនិងការបង្កបង្កើនក្រុម។ ហើយទោះបីជាមានកម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងបីគឺកម្មវិធីទី២ដែលទាក់ទងយ៉ាងច្បាស់ជាមួយជំនួញនឹងសហគ្រាស ដូចជា វិស័យឯកជនដែលដើរតួជាអនុស្ថាប័នដែលប្រែក្លាយជាស្ថាប័នអនុវត្តន៍ ទោះបីជាស្ថិតនៅក្នុងកម្មវិធីទាំងបីក៏ដោយ។ ការអនុវត្តន៍គំរោងធ្វើជំនួញនេះបានក្លាយជាដំណាក់កាលទីបី នៅក្នុងប្រវត្តិនៃស្ថាប័ន **សេដាក** ក៏ដោយក៏ការផ្តោតអារម្មណ៍ជាលើកតំបូងនៅលើការ រីករាលដាលនៃកសិកម្មនិងបន្តបន្ទាប់គឺកម្មវិធីផ្តោតលើការបង្កើតក្រុមនិងពង្រឹងកម្មវិធី។ការវិភាគពីតំណើរការដែល**សេដាក**បានទៅដល់ចំណុចជួបគ្នានេះគឺជាការយល់ដឹងដ៏សំខាន់ ថាតើតុល្យភាពនៃការគ្រប់គ្រងទាក់ទងនឹងការអនុវត្តន៍នៃការអភិវឌ្ឍន៍ដោយចេរភាពនិងការប្រឈមមុខក្នុងការអនុវត្តន៍កិច្ចសហប្រតិបត្តិការណ៍របស់ពួកគេ។

[5] (Yang Saing, 1 August 2007)

*ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ*

និក្ខបទនេះផ្តោតជាតំបូងទៅលើផលិតផលមួយរបស់កសិកម្មសរីរាង្គដែលបានស្រាវជ្រាវនិងផ្សព្វផ្សាយដោយ **សេដាក** ដែលមានឈ្មោះថា **ប្រព័ន្ធប្រពលវប្បកម្មស្រូវ** (បវស) ដែលបានរីកចំរើននៅប្រទេស **ម៉ាដាកាស្កា** ដោយលោកHenri de Laulanié (1993)អ្នកផ្សព្វផ្សាយសាសនាគ្រិះនិកាយយេស៊ូអ៊ីត។ ទ្រឹស្តីដើមរបស់ Laulanié មានដូចខាងក្រោម (យោងតាម Uphoff, 2005):

- ការស្ទូងសំណាបដែលខ្ចី(ក្មេង)ដែលមានអាយុពី ៨-១៥ ថ្ងៃ។
- ស្ទូងសំណាប1ដើមៗដោយបង្កើនគំលាតពីមួយគុម្ពទៅមួយគុម្ពឲ្យស្មើៗគ្នា (ពី ២៥cm ឡើងទៅ)។
- រក្សានូវសំនើមមិនឲ្យមានទឹកជោគជាំពេកនៅក្នុងស្រែ។
- ផ្តល់នូវសមាមាត្រសារធាតុសរីរាង្គឲ្យបានច្រើនជាជាងការដាក់ជីគីមី។
- ត្រូវពិនិត្យស្មៅក្នុងស្រែឲ្យបានញឹកញាប់ ពិសេសគឺ
- ការដកស្មៅដោយដៃឬដោយម៉ាស៊ីន ។

លក្ខខណ្ឌបន្តបន្ទាប់ទៀតរួមមានការស្ទូងជាជួរហើយរាក់ៗ ស្ទូងក្នុងថ្ងៃតែមួយ ព្យួរឲ្យបានញឹកញាប់និងការពង្រាបដីស្រែឲ្យស្មើ ការរៀបចំថ្នាលបណ្តុះ និងការបង្កើនការយកចិត្តទុកដាក់ចំពោះសំណាប និងការជ្រើសរើសពូជ។សារៈសំខាន់ដើម្បីយល់ពីធម្មជាតិរបស់ បវស មានពីគឺ ការទទួលយកអនុវត្តន៍ទាំងស្រុងនិងការរិតបន្តឹងព្រំដែននៃការអនុវត្តន៍ដោយមិនចាំបាច់ដឹងពីការរីកចំរើនក្នុងការផលិតឡើយ។ ក៏ចាំបាច់ផងដែរក្នុងការពន្យល់ឲ្យងាយយល់ដោយផ្អែកលើកត្តាសរុបនៃបទបញ្ហារបស់ផលិតភាពនិងបរិស្ថានរួមមានសក្តានុពលរបស់គ្រាប់ពូជ ទឹក កំលាំងពលកម្មនិងសន្សំជី ជាមួយនឹងការអនុវត្តន៍តែជំហានមួយចំនួន (Satyanarayana et al., 2007; Uphoff, 2003, 2006b) ការបង្កើនជីក្នុងដីជាសក្តានុពលភាពមួយផ្សេងទៀត។

នៅអាស៊ីខាងត្បូងនិងខាងកើតការដាំដុះស្រូវ បវស បានរីកសាយយ៉ាងឆាប់រហ័សហើយក្លាយជាមានប្រជាប្រិយភាពក្នុងបណ្តាអង្គការអភិវឌ្ឍន៍នានាពប៉ុន្តែវាក៏នៅតែបន្តការប្រកួតប្រជែងដោយសមាជិកនៃស្ថាប័នស្រាវជ្រាវក្សេតសាស្រ្តដ៏ធំមួយ។ក្នុងការអនុវត្តន៍ការមិនមានឥទ្ធិពលពីបច្ចេកទេសខាងក្រៅដែលជាបវសជាញឹកញាប់ត្រូវបានទិទានចំពោះលទ្ធផលទាបនៃការផលិតដោយមិនបានបង្កើតនូវការទទួលយកដែលបានគ្រោងទុកដោយក្តីរីករាយជាមួយតែនឹងស្ថានភាពមានដែនកំនត់ហើយនឹងមិនសូម្បីតែភាពដែលអា

ចទៅរួចក្នុងការអនុវត្តន៍ទ្រឹស្តី(Dobermann, 2004; McDonald et al., 2006; Moser & Barrett, 2003; Sheehy et al., 2004; Sheehy et al., 2005)។ ការជំទាស់ដោយចំនុចតស៊ូមតិរបស់បរសទៅលើទិន្នន័យច្បាស់លាស់មួយនឹងបញ្ហាក្នុងវិធីសាស្ត្រជាមួយនឹងការត្រួតពិនិត្យយ៉ាងសំខាន់ដែលជាញឹកញាប់ត្រូវបានចង្អុលបង្ហាញពីការរីកសាយភាយដោយមានការគាំទ្រពីសង្គមស៊ីវិលនឹងការរីករាលដាលយ៉ាងឆាប់រហ័សពីបណ្តាកសិករនៅក្នុងបណ្តាប្រទេសជាច្រើន (Stoop et al., 2002; Uphoff, 2006a)។

## ២.២ ការអនុវត្តន៍ទ្រឹស្តី Actor- Network

ការលេចឡើងនូវវិធីសាស្ត្រនៃការសំណូមពរកើតឡើងពីទ្រឹស្តី (ANT) គឺពាក់ព័ន្ធយ៉ាងសំខាន់ជាមួយការប្រមូលផ្តុំឡើងវិញ ទស្សនៈវិស័យទូលំទូលាយនៃយន្តការរបស់ទ្រឹស្តី សហគមន៍ស្រមោលបានក្លាយទៅជាភាពពិបាកយល់ដដែលៗ។ ដូចដែលលោក Michel Callon បានសសេរថា **ការបំលែងដោយជោគជ័យនឹងធ្វើឲ្យយើងបំភ្លេចយ៉ាងឆាប់រហ័សអំពីប្រវត្តិរបស់វា (Callon, 1986b: 28)**។ ការប្រើប្រាស់ពាក្យ ANT ចំពោះទស្សនៈកសិកម្មសមស្របនិងការអភិវឌ្ឍន៍សហគមន៍របស់ **សេដាក** បានធ្វើអោយទាន់ពេលវេលា (Latour,1987)ជាស្ថានភាពស្មុគស្មាញមួយ និងប្រព័ន្ធកសាងជាប្រវត្តិសាស្ត្រនៃស្ថាប័នអនុវត្តន៍ក្លាយទៅជាការកើនឡើងនូវការមិនចូលគ្នាក្នុងខណៈពេលដែលការធ្វើ និងលទ្ធផលដែលចេញពីប្រព័ន្ធបានរក្សានូវរូបិយភាព។ ដូចការបើកក្បាលរ៉ូបីនេដែលមិនអាចបង្ហាញនូវប្រព័ន្ធចែកចាយទឹកដ៏ស្មុគស្មាញ។

ការអារម្ភកថា ដោយសម្អាងលើការពិសោធន៍និងភ័ស្តុតាងនៃជាតិពិន្ទុវិទ្យាដែលខ្ញុំបង្ហាញដូចខាងក្រោម ខ្ញុំបង្ហាញត្រួសៗនូវពាក្យមួយចំនួនដែលដកស្រង់ចេញពីទ្រឹស្តី Actor-Network ដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងករណីសិក្សានេះ។ ជាបឋមANT គឺពឹងផ្អែកជាចម្បងទៅលើការពិនិត្យនៃតំនើរការរបស់ការបំប្លែង រឺជាយុទ្ធសាស្ត្របង្ហាញនូវស្ថានភាពមួយចំពោះគោលបំនងនៃដំណើរការរបស់អ្នកចូលរួម។ សហគមន៍ស្រមោល គឺជាការបំលែងតំបូងមួយបង្កើតឡើងក្នុងតំបន់អភិវឌ្ឍន៍។ បណ្តាអង្គការ រឺ អ្នកដឹកនាំបង្កើតនូវរង្វាន់នៃការអនុវត្តន៍មនោគមវិជ្ជាសំរាប់ចូលរួមក្នុងសកម្មភាពនានាដែលបង្ហាញពីប្រភពធនធាននៃគំនិតដូចជា ការអភិវឌ្ឍន៍ដោយចេរភាព និងធនធានដែលបានមកពី(ឧ ហិរញ្ញវត្ថុ) ពីការអភិវឌ្ឍន៍ឧស្សាហាកម្ម។ ដើម្បីសំរបសំរួលទៅលើបញ្ហានេះ **ការអភិវឌ្ឍន៍សមស្រប** គឺជាចំណោទមួយក្នុងដំណើរការបង្កើតគំនិត រឺ សកម្មភាពតំបូង (ឧ គំរោងការអភិ

វឌ្ឍន៍ ការបញ្ចូលទៅក្នុងបច្ចេកទេសថ្មី និងចំនេះដឹងខាងបរិស្ថាន -ល-) ដែលវាអាចទាក់ទាញ បង្ខាំង និង ការប្រើប្រាស់នូវតួអង្គជាមនុស្សរឺសំភារៈផ្សេងៗដូចជា បុគ្គលិកតាមតំបន់ បច្ចេកទេស បរស កសិករ ការអនុវត្តន៍ក្នុងវិស័យកសិកម្ម ការិយាល័យ និង ជនបរទេស។ គំរោងរឺបច្ចេកទេសដូចជា បរស **ក្លាយជាអ្នកសំរេចចិត្ត រឺ ជាកាតព្វកិច្ចក្នុងការអោយចូលរួម** នូវសកម្មភាពផ្សេងៗនៃការផ្តើមគំនិតដ៏ទៃទៀតដូចជា វគ្គបណ្តុះបណ្តាល សមាគមកសិករ ក្រុមស្ត្រី និងទីផ្សារសរីរាង្គ។ សកម្មភាពមួយចំនួនដូចជា ការសសេររបាយការណ៍ ការស្ទាបស្ទង់មតិ ការស្នើសុំជំនួយ ការរៀបចំប្រជុំក្រុមអ្នកផលិត ការបោះពុម្ភអត្ថបទស្រាវជ្រាវ បានបំរើជាការងារតូចៗដែលមិនប្រទាក់ក្រឡាគ្នា ដែលជាញឹកញាប់ឆ្លុះបញ្ចាំងពីការត្រួតពិនិតនៃកាងាររបស់ពួកគេ។

## ៣.០ ការសិក្សាបច្ចេកទេសកសិកម្ម និងប្រព័ន្ធផ្តល់អំណាច

## ៣.១ ការបែងចែកកសិករជាក្រុមរបស់ សេដាក

**អ្នកត្រួសត្រាយផ្លូវ** ទស្សនៈវិស័យរបស់ **សេដាក** ប្រជាជនជនបទដែលបានបង្ហាញនូវឆន្ទៈខ្ពស់ក្នុងការចូលរួមនិងការទទួលយកនូវបច្ចេកទេសថ្មីជាធម្មតាត្រូវបានគេសំដៅលើថាជាអ្នកត្រួសត្រាយផ្លូវ។ នៅក្នុងកំរិតខ្លះអ្នកត្រួសត្រាយផ្លូវត្រូវបានជ្រើសរើសផ្លូវដោយខ្លួនឯងពួកគេជាមនុស្សដែលពោពេញដោយទំនុកចិត្ត មានចរិកជាសហគ្រិននិងធនធានសំភារៈដែលកើតចេញពីការស្ម័គ្រចិត្តរបស់ពួកគេ។ ក្នុងករណីផ្សេងទៀតអ្នកត្រួសត្រាយផ្លូវគឺមិនគ្រាន់ចំនាយលើការចូលរួមនិងបានតួនាទីជាផ្លូវការទៀតផង។ ថ្វីបើជាឆន្ទៈតំបូងគឺជាតម្រូវការតិចតួច ដើម្បីឲ្យឃើញក្រៅផ្លូវការថាជាអ្នកត្រួសត្រាយដោយ **សេដាក** អ្នកត្រួសត្រាយមើលឃើញក្នុងទំរង់ខុសៗគ្នាជាច្រើន។ ម៉ី សោម គឺជាអ្នកត្រួសត្រាយផ្លូវតំបូងបំផុតនៃស្រូវ បរស នៅក្នុងប្រទេសកម្ពុជា គាត់គឺជាអ្នករៀបចំអនុវត្តន៍ថ្នាក់ជាតិដែលបានលះបង់យ៉ាងធំធេងក្នុងការបង្កើតថ្មីនៃវិស័យកសិកម្ម ការរៀបចំការអនុវត្តន៍ក្នុងមូលដ្ឋាននិងទស្សនៈវិស័យនៃការរស់នៅដែលបានបង្ហាញ សេដាក និង អ្នកសិក្សាស្រាវជ្រាវ។ ប្រាក់ ជ្រេស គឺជាអ្នកត្រួសត្រាយផ្លូវកំរិតតំបន់នៃស្រូវបរស កសិដ្ឋានពហុប្រយោជន៍និងការគិតគូរពីបរិស្ថានត្រូវបានគេស្គាល់យ៉ាងច្បាស់នៅក្នុងតំបន់២ របស់ សេដាក ។ ទេព ម៉ាប់(ជាឈ្មោះអ្នកស្រាវជ្រាវដាក់អោយ) គឺជាមេភូមិនិងជាកសិករ បរស បានក្លាយជាអ្នកដឹកនាំកំរិតឃុំសំរាប់លទ្ធភាពនៃភាពដឹកនាំរបស់គាត់ហើយនឹងមានវត្តមាននៅក្នុងអង្គការក្នុង

មូលដ្ឋាន។ ដៀនថុន គឺជាវីរៈបុរសកំរិតភូមិទទួលបានស្នាដៃដែលគេដឹងលឺគ្រប់ៗគ្នាចំពោះការខូចខាតផលស្រូវ បរស របស់គាត់នៅឆ្នាំ២០០៤ ប៉ុន្តែបានបន្សល់ទុកនូវការរៀបចំថ្នាក់មូលដ្ឋានជាច្រើន។ ឡប ធីនីន គឺជាអ្នកត្រួសត្រាយផ្លូវម្នាក់ព្រោះគាត់បានធ្វើការសាកល្បងធ្វើស្រូវ បរស នៅឆ្នាំតំបូងដែល សេដាក បានចុះមកក្នុងភូមិរបស់គាត់។ លក្ខខណ្ឌទូលំទូលាយដែលនរណាម្នាក់ត្រូវបានដាក់ឈ្មោះជាអ្នកត្រួសត្រាយផ្លូវដែលស្នើឡើងដោយ សេដាក ក្នុងការប្រើប្រាស់ឈ្មោះនេះដើម្បីផ្តល់កិត្តិនាមដល់កសិករទាំងនេះសំរាប់ការជ្រើសរើស។ សំរាប់អង្គការ សេដាក អ្នកត្រួសត្រាយផ្លូវគ្រប់ប្រភេទទាំងអស់បានក្លាយទៅជាមនុស្សសំខាន់សំរាប់បង្ហាញនជោគជ័យនៃកម្មវិធីកសិកម្មទៅអ្នកផ្តល់ជំនួយហើយជាភ្នាក់ងារមួយចាំបាច់សំរាប់ជាជំនួយការផ្សព្វផ្សាយនិងពង្រីកនូវបច្ចេកទេសកសិកម្មថ្មីនិងការរៀបចំសកម្មភាពរបស់ក្រុម។

ផ្ទុយពីពាក្យជាលក្ខណៈប្រពៃណី **អ្នកត្រួសត្រាយផ្លូវ** គឺជាមនុស្សឯករាជ្យនិងស្វ័យភាព ។ អ្នកត្រួសត្រាយផ្លូវនៅក្នុងបរិបទកម្មវិធីកសិកម្មរបស់ សេដាក គឺជា **កាត៏ឈ្មោះ** ដ៏សកម្ម។ ជាបឋមមានផ្លូវ ២ ក្នុងការប្រើឈ្មោះនេះ ផ្លូវទី១ គឺសំរាប់អ្នកមកមុនតាមការជ្រើសរើសមនុស្សបង្គោលក្នុងមូលដ្ឋានដែលជានិច្ចកាលមើលទៅលើឋានៈរបស់របស់ពួកគេដូចជា មេភូមិ រឺ កសិករដ៏ប៉ិនប្រសប់ដែលគេទទួលស្គាល់។ អ្នកភូមិទាំងនេះត្រូវបានចំណាយចំពោះវាលស្រែសាកល្បងរបស់ពួកគេទៅលើបច្ចេកទេសកសិកម្ម[6]រឺត្រូវបានធ្វើឲ្យថ្លៃថ្នូរដោយបុគ្គលិកដែលជាអ្នកសំរបសំរួលដ៏សំខាន់ក្នុងការអនុវត្តន៍កម្មវិធី។ ជាញឹកញាប់បុគ្គលទាំងនេះត្រូវបានគេឧបត្ថម្ភចំពោះការរៀបចំប្រជុំថ្នាក់ភូមិជាលើកតំបូងរឺការបង្ហាញនូវវាលស្រែសាកល្បង បរស ថ្នាក់មូលដ្ឋានលើកតំបូង។ បុគ្គលដ៏សំខាន់ៗទាំងនេះបានត្រាយផ្លូវសំរាប់ការងារបន្តបន្ទាប់ទៀតការរៃអង្គាររបស់កសិករដែលចាប់អារម្មណ៍ក្នុងកំឡុងពេលនៃការណែនាំនាពេលប្រជុំក្នុងភូមិ។ អ្នកចូលរួមតែងតែបានលឺពីការបង្ហាញក្នុងការចូលរួមដោយបុគ្គលិក សេដាក ហើយបន្ទាប់មកត្រូវបានសួរដោយការលើកដៃរកអ្នកដែលចាប់អារម្មណ៍ក្នុងការសាកល្បងស្រូវ បរស ។ នៅឆ្នាំបន្តបន្ទាប់ទៀតកសិករដែលចាប់អារម្មណ៍ទាំងនេះត្រូវបានអោយតួនាទីជាអ្នក (ត្រួសត្រាយផ្លូវ) ជាពិសេសបើសិនជាពួកគេផ្ទាល់បានក្លាយជាអ្នកឃោសនាស្រូវ បរស ។

---

[6] ការអនុវត្តន៍នៃការស្វែងរកកសិករម្នាក់ៗបានអន់ថយយ៉ាងជាក់ស្តែងនៅឆ្នាំតំបូងរបស់ សេដាក ( ប្រហែលក្នុងឆ្នាំ២០០២) ឥឡូវនេះកិតិសព្ទនិងបណ្តាញដ៏ធំធេងរបស់ សេដាក បានធ្វើឲ្យមាំនូវសំភារៈសំរាប់ការសហការណ៍តំបូង។ តំបូងការចំណាយត្រូវបានផ្តល់អោយដើម្បីធានាដល់កសិករក្នុងការប្រឆាំងទៅនឹងការព្យាយាមអនុវត្តន៍ធ្វើពិសោធន៍ការដាំដុះដ៏គ្រោះថ្នាក់នេះហើយក៏ប្រហែលជាដឹងថាជា ដៃគូស្រាវជ្រាវមួយហើយក៏គ្មាននរណាម្នាក់អាចប្រកែកក្នុងការប្រើប្រាស់នៃការអនុវត្តន៍នេះដើម្បីបង្កើត អ្នកត្រួសត្រាយផ្លូវក្នុងតំបន់រៀងៗខ្លួន។

ដូចដែលកម្មវិធីផ្តួចផ្តើមគំនិតរបស់ សេដាក បានក្លាយជាការបង្កើតឡើងថែមទៀត និងលូតលាស់ឡើងដែលជាឱកាសសំរាប់អ្នកត្រួសត្រាយផ្លូវងាយៗបានកើនឡើងជាច្រើន។ ដូចដែលសំណុំនៃបច្ចេកទេសកសិកម្មបានរីកសាយពី បរស ទៅជាប្រព័ន្ធប្រពលវប្បកម្មបន្លែ ការការចញ្ចឹមសត្វសមស្រប និង កសិដ្ឋានពហុប្រយោជន៍ អ្នកត្រួសត្រាយផ្លូវបានបន្តកាតព្វកិច្ចក្នុងសកម្មភាពផ្សេងៗទៀត។ ជាធម្មតាភាពចាំបាច់ទាំងនេះបានបង្កើនការចូលរួមក្នុងសមាគមកសិករ ក្រុមផលិត ការរៀបចំក្រុមថ្នាក់ឃុំ និងយថាហេតុជាសកម្មភាពសហគ្រាសថ្នាក់ភូមិ។ ការដាក់បញ្ចូលអ្នកត្រួសត្រាយផ្លូវទៅក្នុងតំណែងដែលទទួលខុសត្រូវខ្ពស់ប្រសើជាងតំនើរដ៏ប៉ិនប្រសប់ ប៉ុន្តែមុនពេលពួកគេដឹងរឿងនេះអ្នកត្រួសត្រាយផ្លូវជាច្រើនបានយល់ដឹងកម្មវិធីរបស់ សេដាករួចទៅហើយ ។

***ក្រុមអ្នកចាំមើល*** ដោយឡែកក្នុងខណៈពេលដែលការដាំដុះស្រូវ បរស ធម្មតាគឺមាន **ច្រកចូល**សំរាប់ពង្រីកកម្មវិធីកសិកម្ម មានកសិករជាច្រើនចង់ឲ្យអ្នកត្រួសត្រាយផ្លូវធ្វើពិសោធន៍ដ៏មានហានិភ័យជាមុននៅក្នុងភូមិរបស់ពួកគេ។ ជាញឹកញាប់ពួកគេចង់បង្កើតភាពគ្មានមន្ទិលសង្ស័យថាការដាក់ចំពោះមុខនូវការផ្លាស់ប្តូរការធ្វើស្រែឲ្យសមស្របទៅនឹងប្រព័ន្ធគោលការធម្មជាតីកសិកម្មនិងទំហំនៃផលិតកម្ម។ ជាទូទៅក្រុមរង់ចាំមើលត្រូវបាន សេដាក បង្ហាញឲ្យឃើញតាមរយៈការប្រជុំដោយពាក្យពីមាត់មួយទៅមាត់មួយដែលអាចទទួលយកបបានក៏ដោយក៏ពួកគេបង្កើតនូវហេតុផលផ្សេងៗដោយមិនបានធ្វើពិសោធន៍ក្នុងឆ្នាំដើមតំបូងឡើយ។ ការដកស្រង់ជាបន្តបន្ទាប់ខាងក្រោមនេះនឹងបង្ហាញជាលទ្ធផលជាបែបផែននៃការរង់ចាំ។

> *ក្នុងឆ្នាំ២០០៥ខ្ញុំបានចាប់ផ្តើមធ្វើស្រូវ បរស ដោយបានឃើញកសិករដែលធ្វើនៅឆ្នាំមុនៗទទួលបានផលច្រើនដូចនេះខ្ញុំក៏សំរេចចិត្តធ្វើ បរស សាកល្បងដោយខ្លួនខ្ញុំផ្ទាល់។ ខ្ញុំបានព្យាយាមធ្វើលើផ្ទៃដី ៦អារ។ យើងក៏បានទទួលផលយ៉ាងល្អនៅឆ្នាំនោះ។ចាប់តាំងពីឆ្នាំនោះមកយើងបានទទួលនូវអាកាសធាតុដ៏អាក្រក់និងបញ្ហាដែលមិនទាក់ទងនឹង បរស ដូចជា សត្វចង្រៃនិងគ្រោះថ្នាក់ផ្សេងៗ។ ប៉ុន្តែខ្ញុំដឹងថាបញ្ហាទាំងនេះគឺមិនបានបណ្តាលឲ្យស្រូវ បរស ទទួលបានផលទាបឡើយដូច្នោះនៅឆ្នាំបន្ទាប់(២០០៦) ខ្ញុំបានធ្វើ បរស លើផ្ទៃដីពាក់កណ្តាលនៃដីស្រែរបស់ខ្ញុំហើយនៅឆ្នាំនេះខ្ញុំបានធ្វើ បរស ទាំងអស់ (បុរសអាយុ ៤២ ឆ្នាំ ស្រុកសំរោង)។*

កសិករជាច្រើនដូចជា កសិករទាំងនេះគឺសង្ស័យថាទំនាស់នឹង សេដាក អំពីផលខ្ពស់ រឺ ពួកគេមិនពេញចិត្តនិងបារម្ភថាប្រព័ន្ធថ្មីនេះប្រហែលជាមិនអាចទទួលយកបានរឺមិនសមស្របទៅនិងស្រែរបស់ពួកគេ។ ការខ្វះទំនុកចិត្តផ្សេងៗទៀតគឺសមត្ថភាពរបស់

ពួកគេក្នុងការអនុវត្តន៍ប្រព័ន្ធថ្មីរឺមានអារម្មណ៍ឆោតល្ងង់ខាងផ្នែកសង្គមអំពីការសាកល្បងពីអ្វីដែលថ្មី។ បទពិសោធន៍នៃការមានសកម្មភាពជាតំបូងរបស់នរណាម្នាក់(ឧ ការធ្វើកសិកម្ម) បានផ្លាស់ប្តូរជាមូលដ្ឋានជាជាងការមិនកំនត់អោយកសិករនិងអាចធ្វើគ្មាននូវទំនុកចិត្តរបស់ពួកគេ។

ក្នុងខណៈពេលដែលមានការបង្ខិតបង្ខំអោយទទួលយកការអនុវត្តន៍ទាំងស្រុង ការអនុវត្តន៍ជំហានរបស់ បរស អោយបានច្រើនទៅតាមបច្ចេកទេស បរស តាមដែលអាចធ្វើទៅបានហើយមានន័យថាតំលៃនិងហានិភ័យក្នុងការសាកល្បងធ្វើស្រូវ បរស មានកំរិតទាប។ ទំហំនៃក្រុមចាំមើលច្រើន(ប្រហែល១ភាគ៣ នៃអ្នកដែលខ្ញុំសំភាសទាំងអស់) កសិករអនុវត្តន៍ បរស បានស្នើឡើងថាឧបសគ្គពីសង្គមដ៏ច្របូកច្របល់មានឥទ្ធិពលទៅលើការលំអៀងខាងការធ្វើពិសោធន៍។ ខ្ញុំនិងស្វែងរកបញ្ហាទាំងនេះជាលំអិតនៅពេលក្រោយ។ ទោះបីជាយ៉ាងនេះក្តីឧបសគ្គនេះអាចបំរើជាមធ្យោបាយក្នុងការដកចេញនូវកសិករណាដែលមិនចូលរួមក្នុងការពង្រីកអង្គការ សេដាក និងសកម្មភាពផ្តល់អំណាច។ គ្រាមួយភូមិមួយបានទទួលការបណ្តុះបណ្តាល បរស ជាតំបូងរបស់ពួកគេ ក្រុមចាំមើលគឺស្ថិតនៅលើការសំរេចរបស់ខ្លួនពួកគេផ្ទាល់ ថាតើទទួលយក បរស រឺអត់ហើយពួកគេមិនតម្រូវឲ្យមានអន្តរាគមន៍ពី សេដាក ឡើយ។ ការនិយាយនោះជាគំនិតដើមតំបូងដែលជាលក្ខណៈបុគ្គលរបស់បុគ្គលិកមូលដ្ឋានដែលងប់ងល់ខ្លាំងជានិច្ចកាលតែងតែពុះពារធ្វើការងារនេះដោយស្តាប់បង្គាប់ជាពិសេសនៅពេលដែលវារួមបញ្ចូលនូវសង្គមបុគ្គលសំខាន់និងស្ត្រី។

*ក្រុមពិបាក* នៅក្នុងតារាងដែលបង្កើតដោយកសិករនិងបុគ្គលិកមូលដ្ឋាននៅឯសិក្ខាសាលាមួយ ការ**ខ្វះចំណេះការដឹងខាងបច្ចេកទេសកសិកម្មនឹងភាពខ្ជិលច្រអូស** គឺជាហេតុផលដ៏សំខាន់២ ដែលបណ្តាលអោយពួកគេនៅតែក្រីក្រ (កត់ត្រាតាមតំបន់ ៧ កញ្ញា ២០០៧)។ ហេតុផលទី១ មានផលលើតួនាទីស្របច្បាប់របស់ សេដាក ដូចជា អ្នកផ្តល់នូវចំនេះដឹងបច្ចេកទេសកសិកម្មនៅជនបទក្នុងខណៈពេលដែលហេតុផលទី២ដោះសារយ៉ាងសង្ខេបពីហេតុផលដែលនាំទៅកាន់ការយល់ខុសក្នុងការមិនទទួលយកបច្ចេកទេសទាំងនេះ។ បន្ទាប់មកក្រុមពិបាកត្រូវបានគេស្គាល់ក្រៅផ្លូវការដោយ សេដាក[7] ថាជាពួកកសិករដែលមិនបានចូលរួមក្នុងឱកាសហ្វឹកហាត់បច្ចេកទេសកសិកម្ម ដែលមិនត្រូវបានជ្រើសរើសដាក់ក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មជនបទ[8]។ ចំពោះ សេដាក **ពិបាក** មានន័យថាកសិករ

[7] ខ្ញុំចង់បញ្ជាក់ថា ក្រុមពិបាក មិនមែនជាឈ្មោះផ្លូវការដែលប្រើដោយ សេដាក ឡើយប៉ុន្តែវាជាឈ្មោះក្រៅផ្លូវការនិងជាពិសេសប្រើប្រាស់ដោយបុគ្គលិក សេដាក ពេលដែលជួបប្រទះការពិបាកក្នុងការផ្សព្វផ្សាយ។

[8] (Yi, 21 September 2007)

បានបង្ហាញនូវលក្ខណៈបុគ្គលនិយមដូចជា អភិរក្សនិយម អវិចារណៈភាពរីជាមនុស្សដែលគ្មានចិត្តដែលមានឥទ្ធិពលទៅលើសម្ថភាពរបស់ពួកគេដើម្បីវិនិច្ឆ័យស្រូវ បរស លើគុណសម្បត្តិរបស់ពួកគេ។ អតុល្យភាពបង្ហាញនូវការរួមគ្នាជាមួយនិងមិនជាមួយឧបសគ្គនៃការចូលរួមព្រោះវាសន្មត់ថា បរស គឺជាឧត្តមភាពដ៏វិសេសវិសាលបំផុត ប្រសិនបើមិនគ្រប់ករណីនោះទេក្រុមនេះជាលំដាប់នៃនិយមន័យសំរាប់ការជៀសវាងត្រូវនបានផ្លាស់ប្តូរយ៉ាងសម្បើមហើយអាចត្រូវបានបំបែកដើម្បីកំណត់ថាតើកសិករម្នាក់ **ពិបាក** (ដោយសារលក្ខណៈសម្បត្តិរបស់ពួកគាត់) រីជាឧបសគ្គនៅក្នុងកំរិតនៃសមត្ថភាពរបស់ពួកគេដើម្បីធ្វើស្រូវ បរស។

> *ខ្ញុំប្រហែលជាមិនចង់ផ្តល់អនុសាសន៍ស្រូវ បរស សំរាប់មនុស្សជាច្រើនដ៏ទៃទៀតឡើយព្រោះខ្ញុំគិតថាពួកគេអាចគ្រប់គ្រងដើម្បីធ្វើស្រូវ បរស ដែលបានធ្វើរួចជាស្រេចនិងដឹងអំពីវានៅលើដីរបស់ពួកគេ។ មានតែប្រជាជនតិចតួចប៉ុណ្ណោះដែលបានចាប់ផ្តើមធ្វើនៅឆ្នាំនេះប៉ុន្តែមានមនុស្សជាច្រើនដែលមិនអាចធ្វើបានព្រោះដីរបស់ពួកគេ ( បុរសអាយុ៣៦ ស្រុកត្រាំកក់)។*

ព្រោះតែបុគ្គលិក សេដាក (ជាផលដែលបានពីការហ្វឹកហាត់ និង បទពិសោធន៍) ជឿជាក់ថាមានដំណោះស្រាយយ៉ាងច្បាស់មួយដើម្បីវាយការណ៍ពីឧបសគ្គដែលពួកគេមានបំណងមើលងាយនូវភាពលេចឡើងនៃបុគ្គលសំខាន់ណាម្នាក់។ ក្នុងករណីជាច្រើន **ភាពខ្ជិលច្រអូស** ប្រហែលជាមានន័យដូចនឹងពាក្យ **ឧបសគ្គ**។ ជាឧទាហរណ៍ក្នុងទ្រឹស្តីនៃការដាំដុះស្រូវបរស អាចធ្វើឡើងដោយប្រើប្រាស់កំលាំងពលកម្មតិច ទោះជាយ៉ាងនេះក្តីកសិករជាច្រើនតម្រូវអោយធ្វើពិសោធន៍ពីពីរទៅបីឆ្នាំដើម្បីសំរេចហើយជាពិសេសក្នុងការមើលរំលងនូវការតវ៉ាដោយសុទិដ្ឋិនិយមក្នុងកំឡុងពេលហ្វឹកហ្វាត់។ ពាក្យចចាមរ៉ាមនៅក្នុងសហគមន៍តំបន់អាចបំភ្លើសនូវភាពលេចឡើងនូវការជំទាស់មួយចំនួនដែលបំរើឲ្យជាចម្បងនូវតួនាទីនៃអ្នកមិនទទួលយល់ព្រមជាច្រើន។ ជាឧទាហរណ៍ តថភាពនៃវិទ្យាសាស្ត្របាននិយាយថា ដើមខ្ពស់នឹងការបង្កើនផលដែលជាធម្មតាបានជំទាស់ដោយឥទ្ធិពលអវិជ្ជមាននៃការដាំស្រូវទាបលើការផលិតចំបើងគឺវាមិនអាចប្រឆាំងប្រជែងនិងការផ្សាយដោយចចាមអារ៉ាមថា បរស ផលិតចំបើងតិចហើយប្រហែលជាមានន័យថា គោរបស់គ្រួសារមួយនឹងមានចំណីតិចតួចសំរាប់ជាចំណីនៅរដូវប្រាំង។

តាមពិត **ក្រុមពិបាក** បានបញ្ចូលក្នុងលំដាប់កសិករជាមួយហេតុផលជាច្រើនដែលមិនអាចទៅរួចរីគ្មានឆន្ទៈក្នុងការធ្វើស្រូវ បរស ។ ខ្ញុំក៏បានបង្ហាញផងដែរថា សេដាក បាន

ពណ៌នាក្រុមនេះថា **ពិបាក** ដើម្បីបញ្ជាក់ពីភាពកង្វះក្នុងការកំណត់ឧបសគ្គរបស់ពួកគេ។ ប៉ុន្តែនៅក្រោមហេតុផលថាតើហេតុអ្វីបានជាក្រុមធំកើតចេញពីសកម្មភាពរបស់ សេដាក នេះដូចជាវិសមភាពក្រុមដែលត្រូវបានដាក់នៅគែមដោយសកម្មភាពរបស់ សេដាក គឺដោយសារពួកគេមិនទាមទាធនធានបន្ថែម(ឧ ការតាំងចិត្ត ការពិសោធន៍) ប៉ុន្តែពួកគេថែមទាំងមានឧប្បនិស្ស័យខ្លះៗដើម្បីចូលរួមជាមួយសកម្មភាពដ៏ទៃទៀតរបស់ សេដាក ដែលជាការចាំបាច់សំរាប់ការលូតលាស់របស់ សេដាក ។

## ៣.២ ភ្នាក់ងារយុទ្ធសាស្ត្រ

ក្រុមចុងក្រោយនៃគ្រួសារកសិករដែលខ្ញុំបានជ្រើសរើសសំរាប់ការសិក្សានេះរួមមានអ្នកដែលបើកចិត្តទូលាយនិងឆន្ទៈខ្ពស់ជាមួយនឹងបច្ចេកទេស បរស និងបានរកឃើញជាប្រព័ន្ធក្នុងបរិបទពួកគេ។ ក្រុមនេះគឺដូចគ្នាជាមួយក្រុម **ពិបាក** របស់ សេដាកដែរ ប៉ុន្តែខ្ញុំពន្យល់ថាពួកគេមានយុទ្ធសាស្ត្រនៅក្នុងឥរិយាបទរបស់ពួកគេជាជាង **ការពិបាក** ។ ទស្សនៈបានបើកកកាយឲ្យឃើញនូវការញុះញង់ជាជាងការផ្សះផ្សារនៃការទទួលយកដោយឧបសគ្គរបស់ពួកគេ។ ជាបឋមក្រុមយុទ្ធសាស្ត្ររួមមានអ្នកដែលខំព្យាយាមពុះពារទៅនឹងបណ្តុំនៃឧបសគ្គ អ្នកដែលបានធ្វើពិសោធន៍បរស នឹងបោះបង់វាចោល ហើយពួកគេជាអង្គប្រកបក្នុងប្រព័ន្ធដូចអ្នកដទៃហើយពួកគេត្រូវបានបង្ហាញថាមិសាកសម។ កត្តារួមនៃក្រុមយុទ្ធសាស្ត្រគឺពួកគេមិនអាចទទួលយកបានកម្មវិធីរបស់ បរស ។ នៅក្នុង គ្រួសារកសិករទាំង៧០ដែលខ្ញុំបានជ្រើសរើសដោយចៃដន្យមាន ៣០ភាគរយគឺជាអ្នកមិនទទួលព្រម ។ ទោះបីជាការមិនទទួលយល់ព្រមត្រូវបានបង្ហាញឲ្យឃើញច្បាស់នៃភាពស្មើគ្នា (ភាពយល់គ្នា) នៃស្រែសាកល្បងដែលដឹងដោយកសិករ (Moser & Barrett, 2003) ក៏ដោយក៏ខ្ញុំបានជ្រើសរើសយ៉ាងដាច់ខាតក្នុងការឲ្យនិយមន័យថាកសិករដែលបានសាកល្បងធ្វើស្រូវ បរស ហើយមិនបានជ្រើសរើសធ្វើការសាកល្បងបន្ត។ កសិករមួយចំនួនប្រហែលជាបានដឹងថាមាន **ភាពមិនស្មើគ្នា** នៃការមិនទទួលព្រមដោយសារតែលក្ខណះពិសេសនៃភាពភ័យខ្លាចផ្សេងៗដូចជា អាកាសធាតុមិនល្អ នៅក្នុងឆ្នាំដែលបានសាកល្បង ប៉ុន្តែខ្ញុំអះអាងថាទាំងនេះគួរតែត្រូវបានមើលឃើញថាជាការទទួលយកបានដោយសារតែវាបង្ហាញនូវភាពខ្វះខាត ការដាស់តឿន ការរៀបចំ និងសុទិដ្ឋិនិយមនៃការផ្សព្វផ្សាយកម្មវិធីកសិកម្ម។

ការវិភាគទៅលើការជុំរុញនិងឧបសគ្គចំពោះភ្នាក់ងារយុទ្ធសាស្រ្តនេះគឺឲ្យគុណប្រយោជន៍យ៉ាងពិសេសដូចដែលក្រុមតូច ដែលតំណាងឲ្យកសិករបានលើកទឹកចិត្តយ៉ាងពេញលេញជាមួយកម្មវិធីអភិវឌ្ឍន៍ជនបទរួមមានស្រូវ បរស និង ការជួបប្រទះនឹងឧបសគ្គចម្បងៗផ្សេងៗ។ ជាញឹកញាប់កសិករដែលមិនទទួលយកកម្មវិធី បរស អាចផ្តល់ឲ្យខ្ញុំនូវបញ្ជីនៃឧបសគ្គរបស់ពួកគេ។

> *តាំងពីឆ្នាំ ២០០៤ ខ្ញុំបានឈប់ធ្វើស្រូវ បរស ។ ខ្ញុំទទួលបានផលទាបដោយសារស្រូវមានគុម្ពតូចៗព្រមជាមួយដីដែលគ្មានគុណភាព ការគ្រប់គ្រងទឹក ក្នុងស្រែវាមានការពិបាក។ ខ្ញុំក៏មានដីកំប៉ុស្តខ្លះៗនៅលើដីរបស់ខ្ញុំ ហើយខ្ញុំក៏ត្រូវដោះស្រាយទៅលើបញ្ហាដ៏ធំរបស់ខ្ញុំគឺ បោចស្មៅ។ អូ ត្រូវ ហើយខ្ញុំក៏ទទួលបានចំបើងតិចដែរ( បុរសអាយុ២៩ឆ្នាំ ស្រុកសំរោង )។*

ការដោះស្រាយចំពោះឧបសគ្គរបស់ក្រុមតូចៗដូចទៅនឹងអត្ថន័យនៃការទទួលបានពត៌មានត្រលប់និងការបត់បែន ការវាយតំលៃពីសក្តានុពល ការកែទំរង់និងការធ្វើឲ្យមានភាពរីកចំរើន។

## ៣.៣ ការកេណ្ឌគ្នា

តាមប្រវត្តិសាស្រ្តការពិសោធន៍និងទ្រឹស្តីបានបង្ហាញ សេដាក ថាការអនុវត្តន៍ បរស គឺវាបានបង្កើនផលនិងដោយសារក្រុមសន្សំ ជាដំណោះស្រាយយ៉ាងជោគជ័យទៅលើភាពខ្វះខាតនៃឥណទានជនបទ បុគ្គលិក សេដាក ដែលចុះធ្វើការផ្ទាល់ក្នុងសហគមន៍បានបញ្ជាក់ថាការងារគឺងាយក្នុងការបញ្ចុះបញ្ចូលកសិករឲ្យ **ចូលរួម**។ សំនួរដែលសួរថាតើការដាំដុះស្រូវ បរស គួរតែត្រូវបានអនុវត្តទាំងអស់ដោយពួក កសិករទាំងអស់ និងមានសំនួរថ្មីៗបានលេចឡើងថាតើធ្វើដូចម្តេចដើម្បីអោយប្រជាជនទទួលយក។ ក្នុងន័យនេះទំនាស់លក្ខណៈជាប្រព័ន្ធដូចជាប្រជាជននៅជុំវិញបញ្ហាបរស បដិសេធមិនជុំរុញគំរោងនេះទៅមុខ(Desai,2006)។ ដោយមានការប្តេជ្ញារីការលះបង់របស់ពួកគេទៅលើកម្មវិធីស្រូវ បរស បុគ្គលិក សេដាក បានក្លាយជាភ្នាក់ងារក្នុងការការពារអ្នកខាងក្នុងជាជាងធ្វើជាគ្រូ ហើយផ្ទេររបៀបបង្រៀនរបស់ពួកគេពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

បុគ្គលិករបស់ សេដាក ត្រូវបានចាត់ចូលជាប្រភេទក្រុមសហគមន៍ស្រមោល ដែលផ្តោតទៅលើការជ្រើសរើសមនុស្សនៅក្នុងប្រព័ន្ធរបស់ សេដាក ដោយឆ្លងកាត់ការដាស់

តឿនដោយមិនផ្ទាល់ដូចជាការសន្យាថា បានផលច្រើនទទួលបានផលចំនេញពីការសន្សំ និងលក់ផលិតផលរួម។ ការសាកល្បងជ្រើសរើសជាញឹកញាប់ជឿថាពួកគេកំពុងតែសាកល្បងដាំដុះស្រូវ បរស ដ៏សាមញ្ញនេះ តាមពិតពួកគេបាននៅលើកំនាត់ផ្លូវនៃនូវការផ្សព្វផ្សាយពីសកម្មភាពរបស់ សេដាករួចទៅហើយ ដែល បរស គ្រាន់តែជាចំនុចផ្តើមតែប៉ុណ្ណោះ។ តិចនិចមួយត្រូវបានប្រើប្រាស់ដើម្បីរក្សាការបំលែង ដែលផ្តល់នូវការជ្រើសរើសជាមុខតំណែង(ឧ គ្រូបង្គោលថ្នាក់ភូមិ គ្រូបង្គោលថ្នាក់ឃុំ-ល-)រឺផ្តល់ឲ្យពួកគេនូវឱកាសដើម្បីទទួលបានមុខតំណែងទាំងនេះ(ឧ ប្រធាននៃក្រុមសមាគមកសិករ ហេរញ្ញឹកល )។ ការជ្រើសរើសនេះជាធម្មតាបានរក្សានូវការចាត់ចែងដ៏មមារញឹកចំពោះសកម្មភាពក្រុមផ្សេងៗរបស់ពួកគេដែលប្រើប្រាស់ដើម្បីបង្កើតនូវសំនួរថាតើ បរស គឺជាការសាកល្បងដោយច្បាស់លាស់ចំពោះការជ្រើសរើសនៅក្នុងសហាគមន៍របស់ពួកគេ។

បុគ្គលិក សេដាក ខ្លួនឯងជាញឹកញាប់ពួកគេមិនបានយល់ពីរចនាសំព័ន្ធដើម។ ដោយសារជាធម្មតាពួកគេធ្វើការជាមួយមនុស្សដែលងាយស្រួលក្នុងការជ្រើសរើស ពួកគេមិនបានទទួលយកកម្មវិធី បរស បានឃ្លាតគ្នាកាន់តែឆ្ងាយ។ ភាពមិនសុខស្រួលក្នុងជីវិតរស់នៅនៃមនុស្សទាំងនោះគឺជាកំលាំងរុញច្រានក្នុងការបែងចែកក្រុមជាបីគឺ**ក្រុមអ្នកត្រួសត្រាយផ្លូវ ក្រុមចាំមើល និង ក្រុមពិបាក** ។ វាក៏ជាហេតុផលមួយផង ដែរចំពោះកង្វះនូវប្រភេទគំនិតដែលមានឈ្មោះថា**ក្រុមអ្នកយុទ្ធសាស្រ្ត** ព្រោះដោយសារបុគ្គ លិកខ្លួនឯងផ្ទាល់រស់ក្នុងផ្នត់នៃសហាគមន៍ស្រមោលដែលគ្រប់គ្រងអ្នកចាត់ចែងនិងប្រធាន អ្នកផ្តល់ជំនួយអ្នកសិក្សាលើការអភិវឌ្ឍន៍និងការអភិវឌ្ឍន៍ខ្លួនឯងផ្ទាល់ គំលាតរបស់ពួកគេពី អ្នកយុទ្ធសាស្រ្តបានបញ្ចៀបចូលនូវសកម្មជនដទៃទៀត។

## ៤.0 ការចុះស្រាវជ្រាវដល់កន្លែង : ជ្រើសរើសឧបសគ្គ និងតថភាព

## ៤.១ ការមើលអង្គការសេដាក ដោយតួលេខ

តំបន់សិក្សាក្នុងខេត្តតាកែវដែលជាចំណុចពិសេសចំពោះគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍន៍កសិកម្មនិងជនបទរបស់ពួកគេក្នុងការដាក់បង្ហាញចំពោះអ្នកផ្តល់ជំនួយជាច្រើនដូចជា ភ្នាក់ងារអភិវឌ្ឍន៍និងអង្គការក្រៅរដ្ឋាភិបាលគឺ សេដាក បានធ្វើឲ្យរីកចំរើននូវផលិតផលកសិកម្មរបស់កសិករជាច្រើនគ្រួសារថែមទាំងផ្តល់នូវអំណាចដល់ពួកគេក្នុងការចូលរួ

មគិតជាមួយអ្នកផលិតនិងទីផ្សារឥណទាន[9]។ លើសពីនេះទៅទៀតកសិករបានបង្កើននូវគោលគំនិតធម្មជាតិសំខាន់ៗនិងបុគ្គលិកសកម្មជាច្រើនបានកាត់បន្ថយរឺបានបំបាត់ទាំងស្រុងនូវការប្រើប្រាស់ជីគីមីនិងថ្នាំពុល។ ម្យ៉ាងទៀតទាំងនេះត្រូវបានសម្រេចដោយគ្មានហានីភ័យរឺដើមទុនដែលគ្មានសារៈសំខាន់ទៅក្នុងឧបករណ៍ដែលចាក់គ្រឹះជាយូរលង់មកសំរាប់ធ្វើកសិកម្មរឺគ្រាប់ពូជខាងក្រៅនិងបានជួយធ្វើឲ្យកសិករបង្កើននូវការត្រួតពិនិត្យលើការផ្លាស់ប្តូរទំលាប់នៅក្នុងសហាគមន៍របស់ពួកគេ។ ចំពោះកម្មវិធីផ្តល់អំណាចតំបូងឡើយក្រុមប្រើប្រាស់បានបង្កើតឡើងនូវយុទ្ធសាស្រ្តបានធ្វើឲ្យមានសកម្មភាពជាប្រព័ន្ធដែលនាំទៅរកការឈានមិខក្នុងការីកសាយពីកសិករទៅកសិករ ក្រុមទិញរួមនិងលក់រួម ក្រុមលក់ស្រូវសរីរាង្គ ការរីកចំរើនអភិបបាលកិច្ចក្នុងតំ បន់និងការកើនឡើងនូវមូលធនសង្គម។ ជាមួយនិងគំនិតផ្តួចផ្តើមនៃគំរោងការធ្វើជំនួញរបស់ សេដាកក្នុងឆ្នាំ២០០៧ កសិករដែលបានចូលរួមឥឡូវនេះក៏បានរួមតំណើរសកម្មភាព សហគ្រាសបន្ថែមទៀតដូចជា ការដាក់ភាគហុនក្នុងការកស៊ីក្នុងភូមិ មានមាន់ស្រុក ផលិតផលស្ករត្នោតធម្មជាតិ ទេសចរណ៍ធម្មជាតិ និង ម្ហូបអាហារធម្មជាតិ។ សកម្មភាពរបស់ សេដាក ទាំងនេះជាទូទៅត្រូវបានមើលដោយអនុគ្រោះដោយរដ្ឋាភិបាលជាពិសេសស្រូវ បរស ត្រូវបានគាំទ្រដោយរដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ហើយគោលនយោបាយស្រូវ បរស ត្រូវបានដាក់ក្នុងលេខាធិការដ្ឋាន បរស ដែលជាក្រុមកាងាររបស់រដ្ឋា ភិបាល។ ភ្នាក់ងារអភិវឌ្ឍន៍និងក្រុមអ្នកផ្តល់ជំនួយពីបច្ចឹមប្រទេសជាច្រើនបានមើលឃើញ **សេដាក** ដូចជាអង្គការដ៏ជាទីពេញចិត្តរបស់ពួកគេ ពិសេសមានអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ម្នាក់របស់ទីភ្នាក់ងារអភិវឌ្ឍន៍ជប៉ុន(JICA) បានហៅ សេដាក ថាជា **ក្តីសង្ឃឹមរបស់ពួកយើង** [10]។ សមទ្ធិផលនិងការទទួលស្គាល់ទាំងនេះតាមពិតគឺជាការជួយទ្រទ្រង់នៅក្នុងវិស័យអភិវឌ្ឍន៍ជនបទជាកន្លែងដែលកម្មវិធីអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាបានបង្កើតការពង្រីកនូវភាពជោគជ័យបានតិចតួចបំផុត។

ទោះបីជាយ៉ាងនេះក៏ដោយក៏នៅក្នុងករណីគឺមិនបានទទួលជោគជ័យ ទាំងនេះគឺអ្នកនៅពីក្រោយមានទំនោរទៅរកការទទួលបានឱកាសតិចតួចក្នុងការចាប់យកកម្មវិធីពីអ្នកត្រួសត្រាយផ្លូវ រឺជាសាមញ្ញជាងនេះទៅទៀតពួកគេត្រូវចង់បំភ្លេចចោល។ កំឡុងពេល

---

[9] ទោះបីជាតារាងឈ្មោះនៃ ក្រុមអ្នកគាំទ្រ មានច្រើនក៏ដោយ ក៏ខ្ញុំបានខិតខំប្រមៃប្រមូលនូវទិដ្ឋភាពខាងក្រៅនានារបាយការណ៍ផ្សេងៗនិងការប៉ាន់ប្រមាណនានាដែលអាចរកបាននៅតាមអ៊ីនធើណេតនៃវិទ្យាស្ថានអន្តរជាតិCornelសំរាប់អាហារ កសិកម្មនិងការអភិវឌ្ឍន៍ ( CIIFAD ). Web: http://ciifad.cornell.edu/sri/countries/cambodia/index.html#reports

[10] ន័យដូចនឹងពាក្យទំនាក់ទំនងផ្ទាល់ខ្លួន២៣មិនា ២០០៨ ។

ស្រាវជ្រាវក្នុងសហគមន៍ ខ្ញុំក៏បានជ្រើសរើសដោយចៃដន្យនូវកសិករពីភូមិគោលដៅរបស់ សេដាក ហើយបានប្រៀបធៀបលទ្ធផលពីភូមិដែលលំអៀងជាមួយនិងស្ថិតិរបស់សេដាក ផ្ទាល់ ដែលបានរក្សាទុកនូវ កសិករដែលគ្រាន់តែជាសមាជិករបស់អង្គការសេដាក។ ទីបញ្ចប់ខ្ញុំរកឃើញរបាយការណ៍ដ៏ឥតខ្ចោះថាផលដ៏ពិតប្រាកដ ដែលរបាយការរបស់ សេដាក ភាគច្រើនត្រឹមត្រូវព្រោះថា ជីវភាពសមាជិក សេដាក បានរីកចំរើនក្នុងអំឡុងពេលអនុវត្តន៍គំរោង។ ទោះបីជាយ៉ាងណា ក៏ខ្ញុំបានរកឃើញផងដែរថាផលមួយចំនួនមានភាពសំខាន់ជាតួលេខនៅពេលដែលប្រៀបធៀបទៅនិងលទ្ធផលទូទៅរបស់ភូមិទាំងមូល ខ្ញុំបានរកឃើញថាគ្រួសារកសិករមិនមែន សេដាក បានកើនឡើងផងដែរ រឺ បានប្រសើរឡើងជាងនេះ។

ប្រភពតំបូងរបស់ខ្ញុំសំរាប់ការប៉ាន់ប្រមាណនេះគឺជាផលនៃការវាយតម្លៃរបាយការណ៍ពីកូនសៀវភៅស្តើងជាភាសារអង់គ្លេសនៃការប្រារព្ធខួបទី១០ឆ្នាំរបស់ សេដាក និងតំណាងផ្ទាល់ខ្លួនរបស់ សេដាក។ សំរាប់ការប្រៀបធៀបទិន្នន័យជាបរិមាណ ខ្ញុំបានប្រើការប៉ាន់ប្រមានផលប៉ះពាល់២ ដែលផលិតដោយផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ សេដាក រួមមាន មួយគឺផ្តោតលើផលប៉ះពាល់ថ្នាក់ជាតិ និងមួយទៀតផ្តោតលើតំបន់ដែលខ្ញុំបានធ្វើកាងារផ្ទាល់ (Suon, 2007a, 2007b)។ វាជាជ្រុងមួយដែលខ្ញុំបានវិភាគទៅលើរបាយការណ៍ជាភាសារ ខ្មែរនៅតំបន់២ផ្ទាល់ ថ្វីបើជាទូទៅមិនប៉ះពាល់ជាផ្លូវការដល់តំណាងខាងក្នុងនិងខាងក្រៅរបស់ សេដាកក៏ដោយ។ ឥឡូវយើងចាប់ផ្តើមមើលការបង្ហាញត្រួសៗ២-៣ខាងក្រោម

### *៤.១.១ ផលប៉ះពាល់ទូទៅ*

យោងទៅតាមសេចក្តីថ្លែងការរបស់ប្រធានអង្គការ សេដាកនៅឯវេទិការមួយនាថ្ងៃទី ១៨ មិនា ២០០៨ មានកសិករប្រមាណ៨២០០គ្រួសាររឺ៤.៥%នៃកសិករដែលស្មើនិង២% នៃដីស្រែក្នុងប្រទេសកម្ពុជាបាននិងកំពុងតែអនុវត្តន៍បច្ចេកទេសស្រូវ បរស។ ជាទូទៅ ការវាយតម្លៃអំពីផលប៉ះពាល់ចុងក្រោយពីឆ្នាំ២០០៧បានរាយការណ៍ឲ្យដឹងថាផលចំណូលកសិកម្មជា មធ្យមនៃអ្នកដែលបានចូលរួមបានកើនឡើងពី១,៧លានរៀល(ប្រហែល$៤២៥) ទៅ ២,២លានរៀល(~$៥៥០) ក្នុងអំឡុងពេលពីឆ្នាំ ២០០៤ -២០០៨ (Suon, 2007a)។ ជាមួយនិងតួលេខទាំងនេះបញ្ជាក់ជាបរិមាណនិងគុណភាពដ៏ច្រើនបានលេចឡើងក្តីបារម្មណ៍យ៉ាងពិតប្រាកដ ទំនាក់ទំនងទៅនិងធម្មជាតិ សារៈសំខាន់ជារូមនិងបរិមានរបស់

ពួកគេ។ ទីមួយការកើនប្រាក់ចំណូល(៣០%) ខាងផ្នែកកសិកម្មមិនត្រូវបានគណនាដោយប្រើប្រាស់អំណាចនៃការទិញដូរ (Purchasing Power Parity) និងកើនឡើងនៅពេលមួយដែលអតិផរណាមានចន្លោះពី៥ទៅ១១%(មធ្យម)និងស្ទុះឡើងជិតដល់២០%ក្នុងខែ តំបូងនៃឆ្នាំ២០០៨[11]។ ទី២ការសន្មត់ទៅលើប្រាក់ចំណូលទាំងអស់ត្រូវបានកើនឡើងចំពោះអន្តរាគមន៍របស់គំរោងក្នុងអំឡុងពេលនៃការមិនងអើពើចំពោះក្រុមខាងក្រៅយ៉ាងហោចណាស់វាជាធាតុពិតដែលសេដ្ឋកិច្ចប្រជាជនកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័ស(ពី៥ទៅ១៣%នៃផលិតផលសរុបក្នុងស្រុក) នៅក្នុងឆ្នាំដែលបានធ្វើការវាយតម្លៃ។ ក្នុងខណះពេលដែលកសិករមានជីវភាពក្រីក្រគឺជាអ្វីដែលបានដាក់ឲ្យឆ្ងាយពីឥទ្ធិពលនៃអតិផរណានិងមិនមែនជាសមាសធាតុក្នុងវិស័យទេសចរណ៍និងវិស័យកាត់ដេរដែលបានជួយជំរុញការលូតលាស់របស់GDPរបស់ប្រជាជនដែលសេដ្ឋកិច្ចជនបទមិនត្រូវបានធ្វើឲ្យស្ងប់ស្ងៀមហើយវាបានពឹងលើការកើនឡើងនៃអ្នកប្រើប្រាស់ផលិតផល។ សេដាក មិនដឹងអំពីបញ្ហាតួលេខនេះឡើយហើយក៏បានបញ្ចូលនូវការប៉ាន់ប្រមាណនៃហិរញ្ញវត្ថុដោយការយកចិត្តទុកដាក់អំពីស្តង់ដាជីវិតទូទៅរបស់ពួកគេ(ប៉ុន្តែមិននិយាយពីផលប៉ះពាល់នៃកម្មវិធី)ដូចជា ១៥.៦%នៃរបាយការណ៍ដែលមិនរីកចំរើនទៅតាមស្តង់ដាជីវិតឡើយ ៣៧.២% កើនឡើងបន្តិច ៣៩.៥% កើនឡើងមធ្យម ១.៧% កើនឡើងខ្ពស់ (Suon, 2007a)។ បន្តបន្ទាប់ខាងក្រោមនេះគឺជាលទ្ធផលរបស់ខ្ញុំដែលស្ទើតែនិយាយបានថាវាបានទៅតាមទិសដៅនៃអ្នកភូមិទូទៅព្រោះខ្ញុំបានសកល្បងទៅលើអ្នកចូលរួមនិងអ្នកដែលមិនបានចូលរួមបញ្ចូលគ្នា។ រីក៏អាចនិយាយបានម្យ៉ាងទៀតថាការរីកចំរើនជាច្រើនទាំងនេះត្រូវបានឃ្លាំមើលនិងវាយតម្លៃពីផលប៉ះពាល់របស់សេដាកដែលអាចធ្វើឲ្យគ្រួសារកសិករក្នុងតំបន់ក្រៅពីការធ្វើអន្តរាគមន៍របស់អង្គការ សេដាក។ នេះមិនមែនជាលទ្ធផលដែលគួរឲ្យភ្ញាក់ផ្អើលឡើយវាគួរតែសង្ឃឹមសូម្បីតែភូមិជនបទក៏ពួកគេបានធ្វើឲ្យមានភាពរីកចំរើនសំរាប់ជីវភាពរបស់ពួកគេក្នុងបរិបទនៃការរីកចំរើនខាងសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ នៅក្នុងការសន្និដ្ឋាននេះគឺមិនបាននិយាយថាកម្មវិធីរបស់សេដាក មិនបានធ្វើឲ្យរីកចំរើនខាងជីវភាពនោះឡើយ។ ពិសេសកាត់បន្ថយការប្រើប្រាស់ជីគីមី ការបង្កើននូវមូលធនសង្គម ការទទួលបានឥណទានខ្នាតតូច និងការបណ្តុះបណ្តាលភាពជាសហគ្រិនជាផលវិជ្ជមាន ប៉ុន្តែវាក៏បានស្នើឡើងថាបច្ចេកទេសកសិកម្មធម្មជាតិមិនបាអនុវត្តន៍អោយទូលំទូលាយនិងមានផលប្រយោជន៍នោះទេ។

[11] បានឃើញនូវតួលេខជាផ្លូវការនៃវិទ្យាស្ថានជាតិស្ថិតិ( កម្ពុជា www.nis.gov.kh )

## ៤.១.២ ផលវិបាករបស់កសិកម្មធម្មជាតិ

**តារាង១. Rice land and yield from various reports, 2007**

*ផលស្រូវក្នុងក្រុមអ្នកដែលបានសំភាសពីការសិក្សានេះ*

| | Quartile 1 | Quartile 2 | Quartile 3 | Quartile 4 | Overall |
|---|---|---|---|---|---|
| Total Rice Land (ha/hh) | 0.35 | 0.46 | 0.59 | 0.64 | 0.51 |
| Total SRI rice fields (ha/hh) | 0.14 | 0.28 | 0.19 | 0.45 | 0.26 |
| Total SRI rice fields as a proportion of total | 0.40 | 0.61 | 0.32 | 0.70 | 0.51 |
| Total good SRI rice fields (ha/hh) | 0.12 | 0.30 | 0.22 | 0.43 | 0.24 |
| Total partial SRI rice fields (ha/hh) | 0.19 | 0.27 | N/A | 0.56 | 0.36 |
| Overall rice yield (t/ha) | 2.10 | 2.32 | 2.10 | 2.37 | 2.22 |
| Rice yield excluding SRI (t/ha) | 1.89 | 1.94 | 1.92 | 1.98 | 1.93 |
| Overall rice yield (t/ha) for SRI farmers | 2.39 | 2.68 | 2.33 | 2.54 | 2.49 |
| Rice yield excluding SRI (t/ha) for SRI farmers | 2.01 | 1.80 | 1.79 | 1.69 | 1.83 |
| SRI yield, good SRI fields (t/ha) | 2.57 | 2.92 | 2.57 | 5.03 | 3.07 |
| SRI yield, partial SRI fields (t/ha) | 2.43 | 2.87 | N/A | 2.65 | 2.65 |

*ផលស្រូវដែលរាយការណ៍ដោយសេដាកក្នុងស្រុកសំរោង*

| | Quartile 1 | Quartile 2 | Quartile 3 | Quartile 4 | Overall |
|---|---|---|---|---|---|
| Total Rice Land (ha/hh) | 0.48 | 0.76 | 0.78 | 1.07 | 0.77 |
| Total SRI rice fields (ha/hh) | 0.32 | 0.54 | 0.48 | 0.91 | 0.57 |
| Total SRI rice fields as a proportion of total | 0.67 | 0.71 | 0.62 | 0.85 | 0.74 |
| Total good SRI rice fields (ha/hh) | 0.17 | 0.27 | 0.25 | 0.34 | 0.27 |
| Total partial SRI rice fields (ha/hh) | 0.31 | 0.46 | 0.38 | 0.79 | 0.50 |
| Overall rice yield (t/ha) | 2.48 | 2.26 | 2.84 | 2.34 | 2.48 |
| Rice yield excluding SRI (t/ha) | 1.94 | 1.50 | 2.40 | 1.63 | 1.88 |
| SRI yield, good SRI fields (t/ha) | 3.61 | 2.91 | 3.75 | 3.42 | 3.41 |
| SRI yield, partial SRI fields (t/ha) | 2.74 | 2.56 | 3.20 | 2.33 | 2.74 |

*ផលស្រូវទូទាំងប្រទេស*

| | Quartile 1 | Quartile 2 | Quartile 3 | Quartile 4 | Overall |
|---|---|---|---|---|---|
| Total Rice Land (ha/hh) | 0.83 | 1.21 | 1.38 | 1.89 | 1.33 |
| Total SRI rice fields (ha/hh) | 0.43 | 0.64 | 0.62 | 0.91 | 0.66 |
| Total SRI rice fields as a proportion of total | 0.52 | 0.53 | 0.45 | 0.48 | 0.50 |
| Total good SRI rice fields (ha/hh) | 0.21 | 0.28 | 0.26 | 0.34 | 0.28 |
| Total partial SRI rice fields (ha/hh) | 0.45 | 0.62 | 0.61 | 0.96 | 0.67 |
| Overall rice yield (t/ha) | 1.78 | 1.84 | 1.85 | 1.86 | 1.83 |
| Rice yield excluding SRI (t/ha) | 1.45 | 1.41 | 1.41 | 1.51 | 1.44 |
| SRI yield, good SRI fields (t/ha) | 3.10 | 3.10 | 3.30 | 3.20 | 3.20 |
| SRI yield, partial SRI fields (t/ha) | 2.10 | 2.20 | 2.40 | 2.20 | 2.20 |

កសិករ បរស ទទួលបានប្រាក់ជាមធ្យម ៥១% ពីការធ្វើស្រែ បរស របស់ពួកគេ(របាយការណ៍ សេដាក បានបង្ហាញថា៥៧-៦៦%) ដើម្បីរួមបញ្ចូលបញ្ហានេះតិចជាងពាក់

កណ្តាលនៃប្រាក់បំណាច់ទូទៅនៃស្រែ បរស ទទួលបាន **ផលល្អ** ប្រព្រឹត្តកម្ម បរស[12]បានបន្ថយនូវសក្តានុភាពនៃកំណើនផលស្រូវ។ ក្នុងការសិក្សាទាំងអស់នេះបានរំលឹកឡើងវិញជាមួយនិងគំនិតខ្ញុំផ្ទាល់នូវការរកឃើញពីការប្រៀបធៀបការកើនឡើងផលស្រូវក្នុងមួយហិចតាចាប់ពីលំដាប់កំនើនស្រូវ បរស ពី៤៩-១២២%ប៉ុន្តែទាំងនេះគឺផ្ទុយទៅនិងការកើនឡើងផលស្រូវទាំងមូលដែលមានត្រឹមតែពី15-36% ជាមួយនិងការលេចឡើងនូវការឆ្លុះបញ្ចាំងដ៏ទាបបំផុតនៃតួលេខរបស់ខ្ញុំ( មើលតារាង១ )។

សំនើររបស់ខ្ញុំនៅទីនេះគឺផ្អែកលើការពិពណ៌នានៃតួលេខស្ថិតិប៉ុន្តែវាក៏បានផ្អែកលើការសាកល្បងនិងការវិភាគនៃសេដ្ឋកិច្ចផងដែរ។ ទីមួយការប្រៀបធៀបដោយពឹងលើការវិភាគបែបស្ថិតិបង្ហាញថាផលស្រូវ បរស ទទួលបានខ្ពស់ជាងផលស្រូវដែលមិនមែន បរស លើផ្ទៃដី១ហិចតា។ ម្យ៉ាងវិញទៀតគំរូ ស្ថិតិ ពីរខាងក្រោមបានបង្ហាញថា បរស គឺមិនត្រូវបានគេមើលឃើញថាជាកត្តាសំខាន់ក្នុងការបកស្រាយពីផលស្រូវទូទៅឡើយ(មើលតារាង២) ក្នុងពេលដែលកសិករជាច្រើនមិនបានដាំដុះគ្រប់គ្រាន់នៅលើដីស្រែរបស់ពួកគេដោយប្រើបច្ចេកទេស បរស ។ ជាងនេះទៅទៀតគំរូស្ថិតិ ដែលដាក់ក្នុងតារាង៣បានបង្ហាញថាការដាំដុះបរស គឺមិនមានទំនាក់ទំនងសំខាន់ជាមួយនិងទ្រព្យសម្បត្តិឡើយគឺអាចនិយាយបានថាការដាំដុះ បរស មិនបានបង្កើននូវប្រាក់ចំណូលឡើយ។

**តារាង២. Regression output for two models explaining overall yield**

| | (1)<br>overall yield | | (2)<br>overall yield | |
|---|---|---|---|---|
| cultivation | 0.174$^{+}$ | (1.75) | 0.180$^{+}$ | (1.82) |
| soil type | -0.139 | (-1.23) | -0.126 | (-1.15) |
| organic matter | 0.063 | (0.39) | 0.064 | (0.40) |
| good SRI | 0.216 | (1.06) | | |
| partial SRI | 0.343 | (1.34) | | |
| any SRI | | | 0.254 | (1.34) |
| _cons | 2.284$^{*}$ | (9.03) | 2.261$^{*}$ | (9.12) |
| *N* | 70 | | 70 | |

*t* statistics in parentheses
$^{+}$ $p < 0.10$, $^{*}$ $p < 0.05$

[12] សំនួរដែលសួរថាអ្វីដែលត្រូវបានថ្លឹងថ្លែងថា ល្អ រឺលំអៀង នៃស្រូវ បរស គឺជាការជជែកពិភាក្សាយ៉ាងស្រួចស្រា ង។ ចំពោះកាពន្យល់បកស្រាយផ្នែកស្ថិតិខ្ញុំបានជៀសវាងបញ្ហានេះដោយប្រើនូវកត្តាសំរាប់ពន្យល់បកស្រាយប៉ុន្តែចំពោះផលប្រយោជន៍នៃការប្រៀបធៀបតួលេខរបស់ សេដាក ខ្ញុំបានបង្កើតនូវនិយមន័យដែលសមស្របសំរាប់គំរូនេះដូចតទៅ កសិករម្នាក់ត្រូវបានពិចារណាថាមានភាពលំអៀង( ដូចជាការប្រឆាំងក្នុងបំណងល្អ ) ខាងស្រូវ បរសប្រសិនបើគាត់រឺនាងធ្លាក់ទៅក្នុងលក្ខខណ្ឌទាំងពីរដូចខាងក្រោម (១) ស្ទូងក្នុងថ្ងៃដក (២) អាយុសំណាបតិចជាង២៣ថ្ងៃហើយទី(៣)គំលាតពីមួយគុម្ពទៅមួយគុម្ពយ៉ាងតិច២0cm។

**តារាង៣. Regression output for two models explaining wealth**

| | (1) Wealth | | (2) wealth | |
|---|---|---|---|---|
| avg. yield | 0.404* | (2.21) | 0.407* | (2.22) |
| soil type | 0.228 | (1.37) | 0.275+ | (1.72) |
| Literate | 0.581+ | (1.90) | 0.522+ | (1.73) |
| high-paying job | 0.225 | (0.99) | 0.244 | (1.08) |
| low-paying job | -0.339 | (-1.47) | -0.315 | (-1.37) |
| organic matter | 0.502* | (2.19) | 0.501* | (2.19) |
| residents/hh | 0.095 | (1.31) | 0.071 | (1.03) |
| good SRI | -0.325 | (-1.21) | | |
| partial SRI | 0.049 | (0.15) | | |
| any SRI | | | -0.191 | (-0.81) |
| _cons | -2.414* | (-3.45) | -2.353* | (-3.37) |
| *N* | 70 | | 70 | |

*t* statistics in parentheses
+ $p < 0.10$, * $p < 0.05$

សេចក្តីសន្និដ្ឋានរួមរបស់ខ្ញុំគឺថានៅខណៈពេលដែលការរីកចំរើននៃចំនួនបន្ថែមស្រូវ បរស គឺមានទំនាក់ទំនងជាវិជ្ជមាននឹង(ក៏ដូចជាបុព្វហេតុផងដែរ) ការកើនឡើងនៃផលស្រូវបានជះឥទ្ធិពលទៅលើកំរិតជីវភាពគឺតួលេខឥតប្រយោជន៍ក្នុងការមិនប្រឹងធ្វើស្រូវ បរស ដូចដែលបបានបង្ហាញនូវការប្រើប្រាស់បច្ចេកទេសតិចតួចនិងមានកំនត់ផ្ទៃដីសំរាប់ដាំដុះស្រូវ បរស។ ក្នុងកាងារចុះផ្ទាល់របស់ខ្ញុំនិងការសិក្សាផ្សេងៗនៅក្នុងប្រទេសកម្ពុជា (Rajpal, 2008) បានបង្ហាញថាមានហេតុផលជាច្រើនចំពោះការកង្វះនៃការប្រឹងប្រែងក្នុងការក្លាយរបស់កសិករដែលកំពុងធ្វើ បរស រួមមានឧបសគ្គសង្គមនិងឧបសគ្គជាប្រព័ន្ធដែលអាចជាផលទទួលយកកំរិតទាបនិងការមិនទទួលយកកំរិតខ្ពស់នៅក្នុងការមិនទទួលយកនិងការពិបាកសំរាប់ការពង្រីកបុគ្គលិកក្នុងការជ្រើសរើសនិងការលើកទឹកចិត្តនៃកម្មវិធីរបស់សេដាក ។

## ៤.២ ការទទួលយកការប្រឈមមុខ

ការវិភាគជាបន្តបន្ទាប់នេះគឺផ្អែកលើការសន្មត់ដូចខាងលើដែរគឺថា ទោះបីជាការរីកសាយជាប្រព័ន្ធនិងវិធីសាស្រ្តក្នុងការបង្រៀនដែលកំពុងអនុវត្តន៍ដោយសេដាក មានឥទ្ធិពលយ៉ាងខ្លាំងទៅនិងទំនាក់ទំនងគំរោងអភិវឌ្ឍន៍កសិកម្មជនបទជាច្រើននៅក្នុងប្រទេសកម្ពុជាក៏ដោយក៏មានសំនួរទូលំទូលាយជាច្រើនដូចជា ថាតើការប្រឹងប្រែងទាំងនេះមាន **ឥទ្ធិពលគ្រប់គ្រាន់** (ដើម្បីឈានទៅដល់ទីបំផុតនៃភាពងាយឈឺចាប់មួយភាគនៃចំនួនប្រ

ជាជន) ហើយតើការពង្រីកការផ្សព្វផ្សាយរបស់ សេដាក កំពុងតែមានការរីកចំរើនយ៉ាងមានប្រសិទ្ធភាពក្នុងរយៈពេលកន្លងមកដែររឺទេ។

តំបូងបំផុតវាគឺជាការចាប់អារម្មណ៍ដើម្បីកត់សំគាល់ថាក្រៅពីតួនាទីជាស្នូលរបស់ បរស ក្នុងការជ្រើសរើសចាប់តាំងពីពេលដំបូង រហូតដល់សព្វថ្ងៃនេះគឺជាទិដ្ឋភាពបច្ចេកទេសនៃ បរស ដែលបានទទួលការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ និងបច្ចុប្បន្ននេះសកម្មភាពស្រាវជ្រាវទាក់ទងទៅនឹង ថាតើការយកលំនាំតាម បរស នៅប្រទេសកម្ពុជា និង ប្រជាជនកម្ពុជាបានថយចុះគួរឲ្យកត់សម្គាល់ដូចម្តេច។ ដូចដែលខ្ញុំបានសសេរពីខាងលើរួចហើយទាក់ទងទៅនឹងការយកចិត្តទុកដាក់ពិនិត្យឡើងវិញនូវ **អ្នកយុទ្ធសាស្រ្ត** ដែលនេះគឺជាទិដ្ឋភាពជាក់ស្តែងទូទៅដូចដែលបានពិចារណានូវសក្តានុពលភាពសំរាប់បន្ថែមភាពទទួលព្រមនិងការកើនឡើងនៃការអនុវត្តន៍ស្រូវ បរស ហើយថែមទាំងការប្រមើមើលពីអនាគតក្នុងការជ្រើសរើសសំរាប់ពង្រីកប្រព័ន្ធរបស់ សេដាក។ តាមពិតដោយសារការផ្តោតលើការយកលំនាំតាមស្រូវ បរស របស់កសិករបានចុះថយដែលជាផ្នែករងមួយដ៏ស្ថិតស្ថេរបស់កសិករដែលប្រឈមមុខនិងភាពពិបាកប្រដៅនិងឧបសគ្គបានបន្តឲ្យធ្លាក់ទៅក្នុងបរិបទស្រូវ បរស ទោះបីជាការធ្លាក់ចុះនេះជាផ្នែកមួយនៃកម្មវិធីដ៏ទៃទៀតជាច្រើនរបស់ សេដាក ក៏ដោយ។

*ឧបសគ្គប្រពន្ធ័ចម្បងៗ* និយាយយ៉ាងសង្ខេបដូចខាងក្រោម :

**១ ការគ្រប់គ្រងទឹក** ប្រវត្តិសាស្រ្តតែងតែបានសំរេចថាអ្នកនឹងមានប្រភពទឹកដ៏ល្អនិងអ្នកដែលគ្មានហើយម្យ៉ាងវិញទៀត ការគ្រប់គ្រងទឹកគឺមានឥទ្ធិពលទាំងលើសមត្ថភាពក្នុងការប្រតិបត្តិជំហានជាមូលដ្ឋានរបស់ បរស និងក៏ជាសក្តានុពលចំពោះសុទិដ្ឋិនិយមនៃការរីកចំរើន។ ផលវិបាកគឺត្រូវប្រឈមនិងការជីកប្រឡាយនិងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍គួរត្រូវបានគិតគូរពិចារណាហើយការធ្លាក់ភ្លៀងមិនទៀងទាត់បាននាំមកនូវការផ្លាស់ប្តូរអាកាសធាតុ ហើយមានភាពស្មុគស្មាញទោះបីជាក្នុងប្រព័ន្ធជាប្រវត្តិសាស្រ្តក៏ដោយ។ គ្មានការគ្រប់គ្រងទឹកវាគឺជាការពីបាកក្នុងការរៀបចំគំរោងសំរាប់កំលាំងពលកម្មបន្ថែមទុកជាមុន និង ភាពតូចចង្អៀតនៃការបណ្តុះបណ្តាលបង្កើតនូវអសតម្ពភាពក្នុងការធ្វើផែនការសំរាប់ពិចារណាធ្វើស្រូវ បរស ។ បន្ថែមលើនេះទៅទៀតភាពឥតខ្ចោះក្នុងការធ្វើស្រូវ បរស នៃកំរិតទឹកទាបបានប្រឆាំងនឹងការរស់នៅរបស់កសិករដែលពឹងលើទឹកស្រះសំរាប់ទប់ទល់នឹងភាពរាំងស្ងួតនៅរដូវប្រាំង។

**២ ផលិតផលចំបើង** ផលិតភាពពិភាក្សាដ៏ក្លៀវក្លាបំផុតទៅលើផលិតផលរបស់ បរស ក្នុងចំណោមអ្នកផ្តល់ពត៌ដែលខ្ញុំបានវិភាគ និងការខកការមិនទទួលព្រមដ៏ច្រើនលើស

លប់បានក្លាយជាកត្តាសំខាន់ក្នុងធ្វើអោយយល់ដឹងដ៏តិចតួច។ បុគ្គលិក សេដាក បានអះអាងយ៉ាងដាច់អហង្កការថានៅក្នុងទ្រឹស្តី បរស វាគ្មានបញ្ហាជាមួយនិងការផលិតចំបើងឡើយ។ ដោយសារមធ្យោបាយក្នុងការបង្កើតទិន្នផលចំបើងជាមួយនិងក្របខណ្ឌ បរស បញ្ហានេះជាញឹកញាប់ត្រូវបានបំភ្លេចចោល។ ទោះបីជាយ៉ាងណាការធ្វេសប្រហែសពេកទៅលើបទពិសោធន៍កសិករដែលគ្មានជំនាញបរស ជាធម្មតាគឺឆ្នាំតំបូងរបស់ពួកគេដែលមិនទាន់បានរកឃើញមធ្យោបាយដើម្បីថ្លឹងថ្លែងនូវទិន្នផលចំបើង។ តាមពិតក្នុងចំណោមអ្នកផ្តល់ពត៌មានរបស់ខ្ញុំ ខ្ញុំបានរកឃើញកសិករយ៉ាងតិចតួចបំផុតដែលបានទៅដល់ទ្រឹស្តីនៃផលិតផលចំបើងដែលបានបង្ហាញដោយ សេដាក។ ប្រសិនបើចំបើងមិនមែនជាវត្ថុសំខាន់នៅក្នុងគ្រួសារខ្មែរនិងសត្វចញ្ចឹមរបស់ពួកគេ បញ្ហានេះនិងមិនមានក្តីបារម្ភឡើយ។ តាមពិតខ្ញុំបានរកឃើញថាការរក្សាទុកនូវផលិតផលចំបើងជាស្នឹមចំបើងដូចជា ការរក្សាទុកស្រូវអង្ករក្នុងគ្រួសាររបស់ពួកគេ ជាចំណីគោក្របីរបស់ពួកគេ។ ទោះបីជាយ៉ាងនេះក្តីសេចក្តីអង់អាចមួយនៅក្នុងលទ្ធផលដែល បរស ទទួលបាន គួរត្រូវបានទូទាត់ជាមួយនឹងការទទួលបានផលចំបើងតិច។ ក្តីបារម្ភបន្ថែមទៀតរបស់ខ្ញុំគឺភាពគ្មានឆន្ទះនៃបុគ្គលិក សេដាក ជាច្រើនបានសារភាពថានេះគឺជារឿងពិតដែលប្រឆាំងដើម្បីប្រឌិតបញ្ហាចំពោះកសិករជាច្រើនប៉ុណ្ណោះ។

**៣ ភាពគ្មានប្រភពធនធានគ្រប់គ្រាន់សំរាប់សមាសធាតុសរីរាង្គ** ស្រដៀងទៅនិងផលិតផលចំបើងដែរនេះគឺជាបញ្ហាមួយដែលអាចបញ្ជាក់បានថាគឺជាការរៀបចំដ៏ល្អមួយក្នុងរយះពេលវែងប៉ុន្តែបានបន្សល់ទុកនូវឧបសគ្គដ៏ខ្លាំងក្លាមួយក្នុងការទទួលព្រមដើមតំបូងនិងការកើនឡើងបន្តបន្ទាប់នៃការដាំដុះស្រូវ បរស។ តាមពិតទៅ សេដាក ជាអ្នកប្រឆាំងទៅនិងទំនាក់ទំនងជាមួយជីសរីរាង្គនិងជីអសរីរាង្គ។ ការប្តេជ្ញារបស់ សេដាកដើម្បីកសិកម្មធម្មជាតិបានបញ្ជាក់ថា គាំទ្រនូវការប្រើប្រាស់ជីអសរីរាង្គដូចដែលមានក្នុងការដកស្រង់ដូចខាងក្រោម

> *ខ្ញុំមិនដឹងថាខ្ញុំគួរនិយាយថាវាមានរឺគ្មានបញ្ហាឡើយក្នុងការប្រើប្រាស់ជីគីមីនោះទេ។ខ្ញុំចង់ឲ្យកសិករចាប់ផ្តើមរៀនអំពីបញ្ហាបរិស្ថានប៉ុន្តែខ្ញុំក៏ចង់បញ្ជាក់ថាពួកគេនិងបានផលស្រូវខ្ពស់។ ប្រសិនបើពួកគេចាប់ផ្តើមធ្វើស្រូវ បរស នៅលើដីស្រែដែលគ្មានគុណភាពនោះលទ្ធផលដែលទទួលបានគឺការមិនពេញចិត្តបើសិនបើពួកគេមិនបានប្រើប្រាស់ជីគីមីខ្លះ ប៉ុន្តែវាផ្ទុយទៅនិងការបណ្តុះបណ្តាលរបស់ពួកខ្ញុំក្នុងការផ្តល់នូវអនុសាសន៍( បុគ្គលិកតំបន់ ២ )។*

យើងអាចនិយាយបានម្យ៉ាងទៀតថាការប្តេជ្ញាចិត្តរបស់ សេដាក ដើម្បីធ្វើឲ្យរីកសាយស្រូវ បរស ដែលតំរូវឲ្យមានការបង្កើននូវគុណភាពដីក្នុងដីជាញឹកញាប់មិនអាចសំរេចបានជាមួយនិងប្រភពធនធានដែលអាចរកបានតំបូងបំផុតនៅលើកសិដ្ឋានរបស់គ្រួសារកសិករផ្ទាល់នោះទេ។ មានលក្ខណៈជាប្រវត្តិសាស្ត្រពីមុនៗនៅទីនេះដែលខ្ញុំបានបង្ហាញរួចរាល់ហើយគឺការងើបឡើងវិញពីការបង្ខិតបង្ខំឲ្យប្រើផលិតផលសរីរាង្គក្នុងរបបប៉ុល ពត កសិករខ្មែរបានជ្រើសយកការប្រើប្រាស់ជីគីមីសំរាប់ការសងសឹក។ រយៈពេល ២០-២៥ ឆ្នាំបានកន្លងផុតទៅបានបន្សល់នូវបច្ច័យអាក្រក់ដល់គុណភាពដីដែលផ្អែកលើការបន្ថែមនូវសមាសភាពសរីរាង្គវិញ សកម្មភាពសត្វល្អិតក្នុងដីនិងការធ្វើស្រែសមស្របដែលបានចុះថយនៅពាសពេញប្រទេសកម្ពុជា (Kingdom of Cambodia, 2000)។ ការជំទាស់នេះគឺជាការកសាងគុណភាពដីឡើងវិញគឺជាតំណើរការរយៈពេលវែងក្នុងខណៈពេលដែល សេដាក ជឿជាក់ថាការទទួលយកស្រូវ បរស ជាតំណើរការរយៈពេលខ្លី។ ដោយសារតែការភ័ន្តច្រឡំអំពីតួនាទីនៃជីគីមី កង្វះខាតនូវសមាសធាតុសរីរាង្គនៅលើដីរបស់កសិករ ទំនាក់ទំនងរវាងស្រូវ បរស និងជីគីមីគឺត្រូវតែប្រាប់ឲ្យបានដឹងច្បាស់និងយុទ្ធសាស្ត្រសំរាប់បង្កើនគុណភាពជីក្នុងដីក្នុងរយៈពេលវែងត្រូវតែពន្យល់បកស្រាយ។

*ឧបសគ្គសង្គម*សំខាន់ៗចំពោះការទទួលយកស្រូវបរស ត្រូវបានលើកឡើងយ៉ាងសង្ខេបដូចខាងក្រោម:

**១ ការមិនយកចិត្តទុកដាក់របស់បុគ្គលិក** ការផ្តល់នូវដែនកំណត់នៃប្រភពធនធានសំរាប់ការរីកចំរើន សេដាក បានទទួលយកនូវយុទ្ធសាស្ត្រមួយដែលប្រៀនប្រដៅនៅក្នុងវគ្គបណ្តុះបណ្តាលពីក្រុមល្បាតកសិករបង្គោលក្នុងភូមិនីមួយៗដើម្បីបន្សាយនូវបច្ចេកទេសកសិកម្ម។ នៅក្រោមលក្ខខណ្ឌនេះវាគឺជាធម្មជាតិដើម្បីជ្រើសរើសដោយសាទរនិងឆន្ទៈខ្ពស់បំផុតរបស់អ្នកចូលរួមរៀនទាំងនោះក្នុងពេលដែលតួលេខនេះវាហាក់បីដូចជាមានឥទ្ធិពលបន្ថែមទៀតទៅលើភ្នាក់ងារពង្រីកការសាយភាយ។ ម្យ៉ាងវិញទៀតក្នុងការធ្វើដូចនេះ សេដាក មិនត្រឹមតែគេចវេសនូវការបណ្តុះបណ្តាលផ្ទាល់ទៅលើកសិករដែលមានភាពស្ទាក់ស្ទើរបន្ថែមទៀតប៉ុណ្ណោះទេប៉ុន្តែ សេដាក ក៏បានបាត់បង់នូវឱកាសដើម្បីសិក្សាពីឧបសគ្គដែលប្រឈមមុខនិងកសិករទាំងនោះ។ ជាពិសេសវាបានក្លាយទៅជាមន្ទិលមួយប្រសិនបើវាជាលទ្ធផលដែលបុគ្គលិកបានគេចវេស ការប្រឈមមុខជាមួយនិងគំរូរបស់ពួកគេ។

ដោយភាពសមហេតុផលនេះ ព្រោះតែគ្រួសារជាច្រើនក្នុងខេត្តតាកែវនិយាយដោយឡែក និងនិយាយជារួមនៅប្រទេសកម្ពុជាបានទទួលជោគជ័យជាធម្មតាក្នុងការធ្វើស្រូវបរស វាបានលេចឡើងនូវភាពសមហេតុសមផលកាន់តែតិចឡើងៗសំរាប់អ្នកដែលមិនធ្វើស្រូវបរស។ ជាធម្មតានៅក្នុងចំណោមបុគ្គលិកចុះផ្ទាល់គឺជាការញ្ញាណបង្ហាញថាកសិករដឹងរឺមិនដឹងដោយការសាយភាយ មានតំលៃរឺគ្មានតំលៃចំពោះការយកចិត្តទុកដាក់។ ដោយការផ្តល់សិទ្ធដល់កសិករដែលមានចំណាប់អារម្មណ៍តំបូងគឺមិនត្រឹមតែមានអ្នកចំនាស់ក្មេងៗនិង **ភ្នាក់ងារយុទ្ធសាស្រ្ត**ឡើយជាញឹកញាប់ត្រូវបានដាក់នៅក្រៅពីការខិតខំប្រឹងពីតំបូងដើម្បីផ្សព្វផ្សាយស្រូវ បរស ប៉ុន្តែនៅមានគំ រោងពីរបីសំរាប់ សិក្សា ទៅលើទ្វេគ្រោះដែលប្រឈមមុខចំពោះក្រុមទាំងនោះ ដូចនេះការកំនត់នូវសក្តានុពលភាពចំពោះសេចក្តីសន្និដ្ឋានរបស់ពួកគេក្នុងពេលអនាគត។

**២ បុគ្គលិកធ្វើមិនដឹងមិនលឺចំពោះការបែកបាក់ខាងធម្មជាតិសង្គមនៅក្នុងភូមិគោលដៅ** សេដាក បានធ្វើការនៅលើមូលដ្ឋាននៃឃុំនិងអ្នកដែលចូលរួមទូទៅ ប៉ុន្តែអ្នកត្រួសត្រាយផ្លូវដែលបានចូលរួមតាំងពីពេលចាប់ផ្តើមប្រហែលជាបង្កើតនូវសង្គមពិបាកមួយសំរាប់អ្នកចូលរួមដ៏ទៃទៀតជាពិសេសប្រសិនបើមានប្រាក់ចំណូលខុសប្លែកគ្នាច្រើននោះ។ ជាតំបូងទោះបីជាមានការចាប់អារម្មណ៍ទៅនិងក្រុមនានានិងសមាគមកសិករដែលបើកចំហសំរាប់សមាជិកភាពទាំងអស់ ក៏អ្នកចូលរួមក្រោយៗទៀតប្រឈមនិងហានិភ័យនៃភាពបែកបាក់បន្តិចបន្តួចដែរ។ ទី២គឺគ្មាននូវហេតុផលល្អិតល្អន់ថាហេតុអ្វីបានជាអ្នកណាម្នាក់គួរតែរីករាយដោយជៀសវាងមិនរួចចំពោះបទពិសោធន៍សង្គមនៃការរៀនសូត្រនិងការធ្វើជំនួញជាមួយអ្នកជិតខាងរបស់ខ្លួននោះឡើយ។ ជាពិសេសមានការបែងចែកខណ្ឌសីមាសង្គមដែលមិនលើកទឹកចិត្តក្រុម រឺគ្រួសារក្នុងការចូលរួមក្នុងការប្រជុំទូទៅ។ ទីពកសិករជាច្រើនមានការអៀនខ្មាស់ចំពោះការចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីព្រោះការធ្វើបែបនេះត្រូវបានគេកំនត់សេចក្តីថាជំនាញបច្ចុប្បន្នរបស់ពួកគេគឺមិនពេញលេញ។

**៣ មានឱកាសផ្សេងៗជាច្រើនដើម្បីឲ្យតំលៃចំពោះការទទួលយកស្រូវ បរស** ការទទួលមរតកពីលំហូរក្នុងកាអនុវត្តន៍ទៅលើការអភិវឌ្ឍន៍ជនបទតាមបប្រវត្តិសាស្រ្ត សេដាក មានទស្សនៈវិស័យក្នុងការរក្សាប្រជាជនក្នុងសហគមន៍ដើម្បីការអភិវឌ្ឍន៍ហើយនេះជាអ្វីដែលគេបានរំលឹកឡើង។ សហគមន៍គឺជាកន្លែងសំខាន់តំបូងដែលអាចជួយ**ធ្វើឲ្យប្រជាជនស្នាក់នៅ** គឺជាការកាត់បន្ថយក្តីបារម្មណ៍ (Bakewell, 2007)។ តាមពិតទៅការការពារការចំណាកស្រុកនិងការរក្សានូវអ្នកទទួលផលដូចជា **របបកសិកម្មខ្នាតតូច** គឺជាផ្នែកទូទៅនៃបេសកកម្មរបស់ពួកគេ (CEDAC, 2007)។ ជាការពិតណាស់ចំនាកស្រុកបាន

បណ្ដាលឲ្យកសិករបោះបង់ចោលកសិកម្ម ឧស្សាហកម្មតាមផ្ទះនិងបញ្ហាសង្គមផ្សេងទៀត រួមទាំងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចគឺជាសភាពជាក់ស្ដែងនៃជីវិតជនបទ។ តាមពិតទៅ ៨៥% នៃគ្រួសារកសិករដែលបានធ្វើសំភាសន៍គឺបានចូលរួមក្នុងកាងារក្រៅពីកសិកម្ម, ៥៥% នៃគ្រួសារកសិករយ៉ាងតិចមានកាងារពីរសំខាន់ៗ, ៤៦% នៃគ្រួសារកសិករមានសមាជិកម្នាក់ធ្វើការបាន **កំរៃខ្ពស់**។ កាងារមួយចំនួននេះមានទំនាស់រឺក៏ប្រកួតប្រជែងជា បវស ក្នុងផ្លូវជាច្រើន។ ខ្ញុំបានប្រាប់គ្រួសៗហើយពីវិធីដែលហ្វូងដ៏ធំនៃគោក្របីមានទំនាស់ជមួយ បវស។ បន្ថែមលើនេះទៀតការផលិតស្រានិងស្ករត្នោតធម្មជាតិត្រូវការកំទេចកំទីឈើនិងអុសដ៏ច្រើនសំរាប់ជាថាមពលហើយវាក៏អាចប្រើប្រាស់ក្នុងការផលិតជីកំប៉ុស្តបានដែរ។ ការបង្ខំបន្ថែមទៀតក្នុងការបោចស្មៅ ការរឹតបន្តឹងការគ្រប់គ្រងទឹកនិងតម្រូវឲ្យមានការត្រួតពិនិត្យបន្ថែមទៀតក៏អាចបង្កើតនូវភាពពិបាកចំពោះគ្រួសារធ្វើឲ្យកសិករមិនបានចូលរួមពីការរៀបការនិងពិធីបុណ្យផ្សេងៗ។ កាងារជាច្រើនទៀតអាចមានផលជំលោះដែរប្រសិនបើពួកគេជាប់រវល់ប្រើកំលាំងពលកម្មគ្រួសារដែលគឺជាការសំខាន់( ទោះជាគ្មានភាពចាំបាច់ ) សំរាប់បវស នៅក្នុងរដូវដាំដុះ។

## ៤.៣ សេចក្ដីសង្ខេប វិធីដែល សេដាក បានទៅដល់បច្ចុប្បន្នភាពរបស់ខ្លួន

នៅក្នុងផ្នែកមុនៗខ្ញុំបានសង្ខេបនូវរចនាសម្ព័ន្ធនៃអ្នកទទួលនិងឧបសគ្គសង្គមក្នុងគោលបំណងដើម្បីបង្ហាញពីវិធីដែលបានរីកសាយនៃការអនុវត្តន៍និងស្ថាប័នវប្បធម៌របស់ សេដាក ទាក់ទងក្នុងផ្លូវមួយដែលបានធ្វើឲ្យមានភាពទន់ខ្សោយបន្ថែមទៀតចំពោះ បវស ដែលជាផលប៉ះពាល់ដំបូងមួយទៅលើកម្មវិធីរបស់ សេដាក។ បន្ថែមលើនេះទៅទៀតវិធីដែល សេដាក ដាក់បង្ហាញលទ្ធផលនៃកាងាររបស់ខ្លួនក្នុង **ការប៉ាន់ប្រមាណផលប៉ះពាល់** មិនអនុញ្ញាតឲ្យមានការទិទានជះត្រឡប់មកលើខ្លួនឯងឡើយ។ ឆ្លងកាត់ការបកស្រាយខាងស្ថិតិនិងការត្រួតពិនិត្យឡើងវិញនៃការបង្ហាញទិន្នន័យដែលខ្ញុំបានបង្ហាញថាវាមិនមានការកើនឡើងដោយមើលរំលងនូវការជាប់ទាក់ទង(ស្ថិតិ)និងតួលេខ ភាពមិនសំខាន់និងការបិទបាំងលើកត្តាខាងក្រៅផ្សេងៗដែលមានឥទ្ធិពលលើជនបទប្រទេសកម្ពុជាទាំងមូល។ ខ្ញុំក៏បានបង្ហាញផងដែរថាការកើនឡើងនូវគំលាតគ្នាក្នុងការចូលរួមរបស់បុគ្គលិកក្នុងអង្គការបានឲ្យផលនៅការផ្លាស់ប្ដូរគណនេយ្យភាពដែលកើនឡើងនូវការទទួលរងការចូលចិត្តដែលជំរុញនូវការទាមទារជាយុទ្ធសាស្រ្តដើម្បីដោះស្រាយដោយរួសរាន់ចំពោះកសិករគ្មានពិសោធន៍ជាជាងប្រជាជនសាមញ្ញដែលពេញចិត្តតាំងពីការចាប់ផ្ដើមតំបូងនៃក

ម្មវិធីអភិវឌ្ឍន៍ជនបទ។ ការកើនឡើងនៃគំលាតពី បរស ដូចដែលខ្ញុំបានវែកញែកខាងលើនេះគឺជាការទទួលខុសត្រូវចំពោះការថយចុះការលើកទឹកចិត្តដើម្បីដោះស្រាយជាមួយកសិករដែលមានចិត្តស្ទាក់ស្ទើរនិងការធ្លាក់ចុះនូវសមត្ថភាពដើម្បីដឹកនាំនូវសកម្មភាពស្រាវជ្រាវដែលធ្វើឲ្យ បរស មានកាន់តែច្រើននូវចំណុចចាប់ផ្តើមថ្មីៗ។ សេចក្តីសន្និដ្ឋាននេះគឺមានមតិប្លែកបន្តិចបន្តួចពីព្រោះក្នុងពេលដែលបច្ចេកទេសជាទ្រង់ទ្រាយនៃការរីកសាយ បរស កំពុងទទួលបាននូវការយកចិត្តទុកដាក់តិចតួចដោយ សេដាក ស្រូវ បរសបន្តដើរតួជាចំណុចរាំងស្ទះនៃសកម្មភាពកម្មវិធីអភិវឌ្ឍន៍ផ្សេងៗទៀត។ ការកំនត់នូវឥទ្ធិពលនៃការរីកសាយ បរស បានកំនត់នូវប្លុកនៃសក្តានុពលនៃអ្នកចូលរួមនិងអតិថិជនសំរាប់ សេដាក ក្នុងរយះពេលវែង ឱកាសតិចតួចដែល សេដាក នឹងក្លាយជាអ្នកទទួលខុសត្រូវបន្ថែមទៀតចំពោះក្រុមដែលងាយរងគ្រោះ។ ការពិភាក្សាហេតុអ្វីករណីនេះគឺជាករណីដែលត្រូវផ្តោតនូវផ្នែកខាងក្រោម។

## ៤.៤ សេដាកផ្តោតលើការដើតួជាអ្នកបង្ហាញ

ទោះបីជាស្ថិតក្នុងកាងារក្នុងរយះពេលជាច្រើនឆ្នាំក្នុងពេលប្រារព្វខួបទី១០ឆ្នាំ សេដាកបានចាប់ផ្តើមជាផ្លូវការណ៍ដើម្បីឃោសនានូវមហិច្ឆិតាថ្មីមួយសំរាប់កែប្រែដោយអន្លើៗនូវសកម្មភាពរបស់វាក្នុងការប្រតិបត្តិតាមមុខជំនួញនិងសំដែងខ្លួនជាអ្នកបង្ហាញ។ ថ្វីបើការបែងចែកជាធម្មតាមាននៅក្នុង **កម្មវិធីសំខាន់** ទាំងបីក៏ដោយមានតែកម្មវិធីមួយប៉ុណ្ណោះដែលបានផ្តោតអារម្មណ៍ដាច់ដោយឡែកលើសហគ្រាស ការផ្តោតអារម្មណ៍លើការបង្ហាញពីការធ្វើជំនួញបានជ្រាបចូលគ្រប់តំបន់ទាំងអស់នៃកម្មវិធី(CEDAC, February 2008)។ ជាទូទៅការសំដែងនេះបានទទួលយកការជ្រើសរើសការអភិវឌ្ឍន៍ក្រុមកសិករនិងផលិតផលដែលមានផលចំនេញដូចដែលបានប្រមូលចងក្រងក្នុងរបាយការណ៍ដែលបញ្ជាក់គោលដៅរបស់ខ្លួន។

**ការសសេររបាយការណ៍** ការបំពេញរបាយការណ៍សំរាប់ជាឯកសារនៃ **កិច្ចការជំនួញ** ប្រហែលជាបានគំរាមគំហែងដល់គោលដៅពិតនៃអ្នកចូលរួមដូចជា **អតិថិជន**ជាជាងកសិករដែលមានលក្ខណៈសង្គមស្មុគស្មាញនិងជីវិតរស់នៅរបស់ពួកគេ។ ខណៈពេលបុគ្គលិកភាគច្រើនបានប្រមូលពត៌មានត្រលប់ជាប្រចាំថ្ងៃដែលពួកគេបានជួប។ ការសសេររបាយការណ៍មួយចំនួនបានកែប្រែយ៉ាងឃើតៗពីធម្មជាតិនៃបទពិសោធន៍នេះ។ ទស្សនៈតាមជំនឿរបស់បុគ្គលិកបានផាត់ពណ៌បន្ថែមទៀតដោយការផ្សព្វផ្សាយរបស់ពួកគេដើម្បីប្រាប់

ពីផលប៉ះពាល់នៃវិធីសាស្រ្តក្នុងការប៉ាន់ប្រមាណនិងរូបបមន្តនៃការសសេររបាយការណ៍ (Desai, 2006: 178)។ ឆ្លងតាមការស្រាវជ្រាវឯកសារសំខាន់របស់ខ្ញុំក្នុងតំបន់២ខ្ញុំក៏បានរកឃើញថាបុគ្គលិកចុះផ្ទាល់ជាច្រើនបានចាប់ផ្តើមបកស្រាយនៅក្រោមការទាមទារនៃប្រព័ន្ធត្រួតពិនិត្យរបាយការណ៍របស់ សេដាក។ នៅក្នុងរបាយការណ៍របស់ពួកគេពួកគេបានសសេរសាចុះសារឡើងនូវពាក្យនិងគំនិតសំខាន់ដដែលៗសំរាប់រៀបចំអ្នកតំនាងកាងាររបស់ពួកគេនៅក្នុងតំបន់ផ្ទាល់ (Desai, 2006: 177)។ ចំណែកខ្លះនៃភាពមិនត្រូវការនេះគឺត្រូវបានបណ្តាលមកពីការទទួលបន្ទុកនៃការសសេររបាយការណ៍ដែលបង្ខំឲ្យបុគ្គលិកចុះផ្ទាល់ដើម្បីទទួលយកនូវយុទ្ធសាស្រ្តសេដ្ឋកិច្ចចំពោះការសសេររបាយការណ៍។

**ការបង្កើនសហគ្រាស**ជាទូទៅការដើតួជាអ្នកដឹកនាំគឺមានន័យថា **សហគ្រាស** ក្លាយជាថ្នាក់ខ្ពស់បំផុតនៃសកម្មភាពរបស់អង្គការបើទោះបីជាវាពឹងលើស្ថេរភាពនៃរចនាសម្ព័ន្ធរបស់អង្គការក៏ដោយ។បន្ទាប់ពីការវិវត្តន៍ពីសាលាសហគមន៍កសិករទៅសមាគមកសិកររួចទៅក្រុមថ្នាក់ឃុំ មុខជំនួញនិងសហគ្រាសគឺត្រូវបានមើលឃើញថាជាជំហានបន្ទាប់។ កសិករត្រូវតែ សំអិតសំអាង សំរាប់ប្រព័ន្ធរបស់ សេដាក ដើម្បីធ្វើឲ្យពួកគេមានដៃគូរដ៏សមស្របជាមួយក្របខណ្ឌនៃគំរោងការជំនួញថ្នាក់ជាតិ។ ដើម្បីក្លាយជាដៃគូរកសិករក្រុមកសិករត្រូវតែដើរតាមផ្លូវដែលរៀបចំដោយ សេដាក ដែលរួមបញ្ចូលនូវបញ្ញត្តិនៃការវិវត្តិរបស់អង្គការខ្លួនជាបន្តបន្ទាប់។ ជាលទ្ធផលសមាគមកសិករបានបង្កើតនូវដើមកំនើតនៃវេទិការអភិវឌ្ឍន៍សហគម( Mishra et al, 2006) ហើយក៏បំរើជាបណ្តាញដឹកនាំឆ្ពោះទៅរកសកម្មភាពសំរបសំរួលជាក់លាក់របស់បណ្តាញថ្នាក់ក្រោម (Wright, 1994)។

> *ពីរបីឆ្នាំមុនកូនប្រសារប្រុសរបស់ខ្ញុំបាននិយាយថាគាត់គ្រាន់តែចង់សាកល្បងធ្វើស្រូវ បរស។ នៅឆ្នាំបន្ទាប់ទៀតគាត់បានចូលរួមនៅក្នុងសហគមកសិករ។ នៅឆ្នាំបន្ទាប់ទៀតគាត់គឺជាហិរញ្ញិកនិងបន្ទាប់ទៀតបានចូលរួមក្នុងគណកម្មការថ្នាក់ឃុំ។នៅឆ្នាំក្រោយទៀតគាត់ចង់ធ្វើជំនួញជាមួយ សេដាក។ ខ្ញុំគិតថាមនុស្សជាច្រើនក្នុងភូមិនឹងដើរតាមផ្លូវនេះ។ ខ្ញុំស្មានថាខ្ញុំបាត់បង់ឱកាស( បុរសអាយុ៥៣ឆ្នាំ ស្រុកត្រាំកក់ )។*

ខ្ញុំជជែកវែកញែកថាសហគមន៍កសិករក្នុងពេលដែលវេទិការបើកចំហរតាមទ្រឹស្តីត្រូវបានត្រួតពិនិត្យដោយភាពទំនាក់ទំនងជាអនុភាពជាមួយ សេដាក។ ប្រធានកម្មវិធីនៅក្នុងតំបន់២បានអធិប្បាយប្រាប់ខ្ញុំថាសមាគមកសិករគឺជាអ្នកនាំទៅរកទិសនៃការផ្តល់អំនាចព្រោះ សេដាក គ្រាន់តែជាអ្នករៀបចំរចនាសម្ព័ន្ធសំរាប់ការរីកសាយពីកសិករម្នាក់ទៅម្នាក់ទៀតប៉ុណ្ណោះហើយបន្ទាប់មកបានទុកជោគវាសនារបស់សហគមកសិករនៅលើដៃនៃស

មាជិករបស់ខ្លួន។ តាមពិតទៅសមាជិកទាំងអស់ធ្វើការចែករំលែកនៃចំនេះដឹងកសិកម្មនិងរៀនពីរបៀបធ្វើការជាមួយគ្នាដើម្បីការអភិវឌ្ឍន៍ឋាន: និងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំនិងពិភាក្សាបញ្ហាសំខាន់ៗដែលប្រឈមមុខនៅក្នុងភូមិរបស់ពួកគេ។ ជាពិសេសទៅទៀតសមាគមកសិករសំរេចជោគជ័យក្នុងការផ្តល់នូវវេទិកាសំរាប់ការផ្តល់អំនាចដល់អ្នករស់នៅក្នុងភូមិ។ម្យ៉ាងវិញទៀតរាល់សកម្មភាពនិងរចនាសម្ព័ន្ធជាផ្លូវការរបស់សមាគមកសិករត្រូវបានបញ្ញត្តិដោយបុគ្គលិកចុះផ្ទាល់របស់ សេដាក។ ជាអាថិគឺគ្រប់សមាគមកសិករទាំងអស់ទទួលយកតិចរឺច្រើនពីប្រព័ន្ធគ្រប់គ្រងដូចគ្នា(ជាញឹកញាប់ដូចនិងការបង្កើតឯកសារ) ហើយសមាគមកសិករស្ទើតែទាំងអស់មានលក្ខណះដូចគ្នារួមមានក្រុមចងការប្រាក់និងសកម្មភាពឥណទានខ្នាតតូច។ លើសពីនេះទៅទៀតសមាគមកសិករជាញឹកញាប់មានលក្ខណះបូរាណនិងបង្កើតនូវការផ្តួចផ្តើមគំនិតដូចជា កម្មវិធីជួយពេលរៀបការ ថ្លៃឈ្នួលសំភារៈ អ្នកណែនាំស្មគ្រចិត្តទៅលើការស៊ីស្មៅរបស់គោក្របីនិងការបោះពុម្ពកាសែតតាមភូមិ។ សមាជិកសមាគមកសិករបានស្នើឡើងនូវសកម្មភាពទាំងអស់នេះមកខ្ញុំប៉ុន្តែខ្ញុំមានអារម្មណ៍ថាសំពាធដ៏តូចចង្អៀតបានធ្វើឲ្យវាពិបាកសំរាប់ពួកគេក្នុងការណែនាំដូចជាសកម្មភាពថ្មីៗចំពោះសមាគមកសិករ។ សមាគមកសិករត្រូវបានមើលឃើញថាជាកន្លែងនៃការបណ្តុះបណ្តាលថ្នាក់ក្រោមដែល **រួមបញ្ចូល** បច្ចេកទេសនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើតនូវដៃគូរជនបទដ៏មានសក្តានុពលសំរាប់ សេដាក។ ជាលទ្ធផលផ្លូវនេះចំពោះក្រុមពតិមាននិងការទាមទារឲ្យមានសមាគមជំនួញជាមួយប្រជាជនជនបទ វាមាននូវកន្លែងដ៏តូចសំរាប់ការកែប្រែនូវរចនាសម្ព័ន្ធមូលដ្ឋានដែលមានឥទ្ធិពលលើគណ្យនីយភាពរបស់ សេដាក ចំពោះក្រុមដែលងាយរងគ្រោះថែមទៀត។

## ៥.០ ការសន្និដ្ឋាននិងការពិភាក្សា

ភស្តុតាងដែលបានបង្ហាញនៅទីនេះទាក់ទងទៅនឹងការទទួលយកស្រូវ បវស ការបង្កើតក្រុមនិងការវិវត្តន៍នៃការគ្រប់គ្រងគឺមានបំនងដើម្បីបង្ហាញឲ្យឃើញនូវបរិធាននៃការអភិវឌ្ឍន៍របស់ សេដាកដូចជាអង្គការមួយដែលមើលឃើញកាងាររបស់ខ្លួនជាភាពចាំបាច់នៃការអភិវឌ្ឍន៍ដោយចេរភាពដូចដែលបានបំលែង(**ការកសាងនូវបណ្តាញកាងារ**)ប្រែជាការងារសំខាន់របស់ខ្លួន។តាមពិតបញ្ញត្តិនៃនិរន្តភាពគឺជាការអះអាងផ្ទាល់ខ្លួនដែលវាគឺជាការឲ្យនិយមន័យជាទូទៅនៅក្នុងការបូកបញ្ចូលនូវរបៀបរបបដើម្បីពណ៌នាជាសមញ្ញអំពីការវិវត្តន៍នៃការគ្រប់គ្រងដូចជាយុទ្ធសាស្រ្តនឹងការកំនត់ឡើងវិញនៃប្រភពធនធានដើម្បី

សំរេចបានកាន់តែប្រសើរក្នុងការអភិវឌ្ឍន៍ដោយចេរភាព (Adams, 1995: 87)។ និយម ន័យដើមតំបូងដូចជាបរិស្ថានក្នុងការបង្កើនការផលិតកសិកម្មដំណាំស្រូវក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍន៍ចេរភាពមានការពេញនិយមម្តងទៀតដូចជាការធ្វើឡើងជាផ្លូវការ។ ជាញឹកញាប់ទីផ្សារដែលត្រូវពឹងលើបណ្តាញកាងារនៃអ្នក ផលិតដែលបានសំរបសំរួលដោយសេដាក។ ការធ្វើឲ្យរីកចំរើននូវជីវភាពជនបទបានប្រែ ក្លាយដោយរីកសាយប្រព័ន្ធផលិតផលជាជាងសកម្មភាពមួយរបស់វា។ ភាពផ្លាស់ប្តូរនៅក្នុងគណ្បនីយភាពកើនឡើងពីការថមថយដ៏សំខាន់ក្នុងការរីកសាយនៃវិ ស័យកសិកម្មគឺជាសញ្ញានៃការមើលឃើញអង្គការមួយធ្វើឲ្យប្រសើរឡើងនូវកំរិតជីវភាពដូចជាមាតិការនៃការសំដែងផ្ទាល់ខ្លួនរបស់វាជាជាងគោលដៅត្រឹមត្រូវ។ នេះគឺមិនមានន័យថា សេដាកប្រាថ្នាឲ្យមានអ្នកចូលរួមតិចតួចនៅក្នុងកម្មវិធីរបស់ខ្លួននោះទេប៉ុន្តែគឺជាការដឹងគុណចំពោះការយកចិត្តទុកដាក់លើការសំដែងផ្ទាល់ខ្លួនដើម្បីឈោងដល់ប្រព័ន្ធដែមានការលើកទឹកចិត្តតិចតួចដើម្បីទៅដល់ការជ្រើសរើសជាបន្ទាប់បន្សំដែលជាតំលៃនៃការជ្រើសរើសមានការកើនឡើងជាលំដាប់តាមប្រព័ន្ធនិងឧបសគ្គសង្គម។

ក្នុងពេលដែលតំលៃនៃការជ្រើសរើសនិងការរីកសាយភាយតំលៃនៃការកើនឡើងគណ្បនីយភាព អាចត្រូវបានកាត់បន្ថយដោយការបង្ហាញពីឧបសគ្គសង្គមនិងឧបសគ្គជាប្រព័ន្ធដែលខ្ញុំបាននិយាយត្រួសៗ ខ្ញុំបានបង្ហាញថា ការរីកលូតលាស់ ភាពរឹងប៉ឹងនៃបរិបទគ្រប់គ្រងជាការវិវត្តន៍ដែលធ្វើឲ្យ កើនឡើងនូវភាពគ្មានលទ្ធភាពសំរាប់តម្រូវចិត្តទៅតាមការប្រែប្រួលដ៏ចាំបាច់ក្នុងការធ្វើដូច្នេះ។ ឧបករណ៍វាស់នៃការអនុវត្តន៍របស់សេដាក ក្នុងឆ្នាំតំបូងៗដែលរួមបញ្ចូលទាំងសកម្មភាពស្រាវជ្រាវនិងផលប៉ះពាល់នៃឧបសគ្គនៅជនបទគឺការកើនឡើងយ៉ាងសន្ធឹកសន្ធាប់រីក៏បានបង្ហាញឲ្យឃើញដូចជាការដើរថយក្រោយនៃភាពគ្មានសេដ្ឋកិច្ចទៅកាន់តួនាទី **ចាស់** នៃមុខងារក្នុងសភាពនៃការសំដែងជាអ្នកដឹកនាំថ្មី។ ការប៉ាន់ប្រមាណពីផលប៉ះពាល់និងការសសេររបាយការណ៍សាបព្រួសនូវភាពមិនច្បាស់លាស់ពីអតីតកាលនិងការការពារជោគវាសនានិងការពន្យល់បកស្រាយដែលអាចបត់បែនបានអំពីទីកន្លែងដែល សេដាក កំពុងទៅ ដោយផ្តោតលើកាងារបច្ចុប្បន្ន។ ពាក្យបង្គាប់បញ្ជាថ្មីៗលេចឡើងពីការដើតួជាអ្នកសំដែងគឺដើម្បីបញ្ជាក់ថាការរីកសាយ(ឧ.ការកេណ្ឌគ្នា) គឺ **មានឥទ្ធិពលគ្រប់គ្រាន់** ដើម្បីរក្សាទុកនូវជំនួយបរទេសនិងដើម្បីឧបត្ថមសហាគមន៍ស្រមោលរបស់ សេដាក ជាមួយនេងការធ្វើអោយគ្រប់គ្រាន់ ដើម្បីពង្រីកការជ្រើសរើសថ្មីៗ។ វាជាការច្បាស់ណាស់ថាទំនាក់ទំនងដ៏ជោគជ័យរបស់ សេដាក ជាមួយនិងការសាយភាយនៃស្រូវ បរស និងការបង្កើតក្រុមដែលមានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំង ប៉ុន្តែតួ

លេខនេះបានបិទបាំងនូវកត្តាសំខាន់ផ្សេងៗនិងទំនាក់ទំនងមិនពិតជាច្រើនអំពីឥទ្ធិពលរបស់ខ្លួនក្នុងសហាគមន៍ជនបទ។ នេះជាការសន្និដ្ឋានរបស់ខ្ញុំថា នៅពេលថ្មីៗនេះ សេដាក បានផ្លាស់ប្តូរដើម្បីតំរង់ទិសនៃការអភិវឌ្ឍន៍សហាគមដែលសំដៅទៅរកចម្លើយមួយដើម្បីកែប្រែសង្គម **និរន្តភាពទីផ្សារដែលជាគំរូនៃការអភិវឌ្ឍន៍ដោយចេរភាព** (Adams, 1995)។ក្នុងពេលមានការរិះគន់គំរូនេះគឺមិនមែនជាព្រំដែននៃកាងារនោះឡើយ ក្នុងក្តីសង្ឃឹមនាពេលអនាគត ខ្ញុំនឹងសន្និដ្ឋានជាមួយនិងការពិភាក្សាត្រួសៗអំពីលទ្ធផលល្អសំរាប់គំរូនេះដើម្បីប្រឈមមុខទៅនឹងទំរង់ឧស្សាហកម្មប្រពៃណីនៃការអភិវឌ្ឍន៍កសិកម្មរឹក៏ស្របគ្នា។

ខ្ញុំផ្តោតលើស្រូវ បរស នៅក្នុងនិក្ខបទនេះពីព្រោះនៅក្នុងខេត្តតាកែវវាបានក្លាយជាអ្នកសំរេចចិត្តនូវគ្រប់សកម្មភាព និងសំភារៈតិចទានទៅលើគណ្យនីយភាព។ កសិករស្ទើរតែទាំងអស់ដែលបានរៀន បរស ជំហានតំបូងបានក្លាយជាសមាជិកសំខាន់របស់ ប្រព័ន្ធសេដាក ដែលអាចរួមបញ្ចូលនូវសកម្មភាពជាច្រើនដូចជា ការចញ្ចឹមសត្វតាមលក្ខណៈធម្មជាតិ ឥណទានខ្នាតតូចក្នុងភូមិ ក្រុមអ្នកចងការប្រាក់ ក្រុមអ្នកផលិត ការសាយភាយពីកសិករទៅកសិករ និងសកម្មភាពទាក់ទងនិងជំនួញ។ ភាពអសមត្ថភាពនិងភាពគ្មានឆន្ទៈដើម្បីធ្វើស្រូវ បរស ជាទូទៅធ្វើអោយកសិករចូលរួមផ្នែកខ្លះទៀតសកម្មភាពផ្សេងៗ ដូច្នេះការធ្វើស្រូវ បរស ជា **កត្តព្វកិច្ចដែលត្រូវតែសាកល្បង** (Callon, 1986a: 26-27)។ ខ្ញុំបានផ្តល់នូវការចូលរួមដ៏សំខាន់ទៅលើរចនាសំព័ន្ធ និងឧបសគ្គសង្គមដែលសំរុះសំរួលរឺមិន ចំពោះគ្រួសារកសិករដែលអាចឆ្លងកាត់អ្នកយាមទ្វា បរស ព្រោះឧបសគ្គទាំងនេះមានឥទ្ធិពលទៅលើការព្យាករណ៍ថាតើកសិករអាចរឺមិនអាចចូលរួមក្នុងប្រព័ន្ធសេដាក[13]។ ខ្ញុំបានសន្និដ្ឋានថាការផ្តល់នូវសមត្ថភាពជាប្រវត្តិសាស្រ្តរបស់ សេដាក ដើម្បីដោះស្រាយជាមួយឧបសគ្គទាំងនេះដូចដែលបានឃើញ ដោយឯកសារដែលបានកត់ទុកពីមុននូវប្រសិទ្ធិភាពរបស់សកម្មភាពស្រាវជ្រាវក្នុងវិស័យកសិកម្ម សេដាក បានអនុញ្ញាតឲ្យទទួលយល់ព្រមនូវឧបសគ្គទាំងនេះដើម្បីតស៊ូជំនះ ពីព្រោះពួកគេបានជួយជ្រើសរើសដៃគូរដ៏សមស្រប។ អាចនិយាយបានម្យ៉ាងទៀតថាឧបសគ្គជាតំរងរឹកញ្ចក់ធម្មជាតិដែលបញ្ជាក់ថាកសិករណាដែលមានតំលៃកាងារជាមួយ(ឧ ងាយស្រួលកេណ្ឌនិងឆន្ទៈដើម្បីពង្រីកប្រព័ន្ធ សេដាក) នឹងកសិករណាដែលគ្មានតំលៃ(ឧ រួមបញ្ចូលទាំការមិនសាទរចំពោះកសារចូលរួមក្នុងសកម្មភាពទាំងឡាយរបស់អង្គការ)។ ក្រុម **គ្មានតំលៃ** នេះត្រូវបានឲ្យនិយមន័យក្រៅផ្លូវការ

[13] ដើម្បីយកកន្លែងនៃការរិះគន់ផ្ទាល់នៅទីនេះខ្ញុំគួរតែចង្អុលបង្ហាញថាតែងតែមានការលើកលែងចំពោះកសិករមិន បរស ដែលចូលក្នុងសមាគមកសិករនិងកសិករ បរស ដែលមិនចូលរួមក្នុងសមាគមកសិករ។ ទោះបីជាមានវគ្គនៃរឿងផ្ទាល់ខ្លួនទាំនេះក៏វាមិនប៉ះពាល់ដល់សេចក្តីសន្និដ្ឋានរួមរបស់ខ្ញុំដែរ។

ដាច់ដោយឡែកដោយ សេដាកថា **ក្រុមពិបាក**[14] ជាកសិករទាំងឡាយណាដែលត្រូវបានថ្លឹងថ្លែងដោយអព្យាក្រិត្យដោយ សេដាក ដូចជា **លើសពីសមត្ថភាពរបស់ពួកគេ** ក្នុងការដាក់បញ្ចូល។ ផ្ទុយទៅវិញ **ក្រុមមានតំលៃ**ត្រូវបានមើលឃើញនិងយល់ព្រមថាជា **អ្នកត្រួសត្រាយផ្លូវ**។ ក្រុមទីពគឺ **ក្រុមចាំមើល** រួមបញ្ចូលនូវកសិករដែលបានរឺមិនបានចូលក្នុងក្រុមអ្នកត្រួសត្រាយផ្លូវ និង ក្រុមពិបាក។ ការវិភាគរបស់ខ្ញុំចំពោះឧបសគ្គសង្គមនិងឧបសគ្គប្រព័ន្ធបង្ហាញថានៅមានក្រុមដាច់ដោយឡែកមួយទៀតគឺ **ភ្នាក់ងារយុទ្ធសាស្ត្រ** ដែលរួមមានសមាជិកក្នុងក្រុមចាំមើលនិងក្រុមពិបាកយ៉ាងច្រើនដែលចូលរួមជាមួយ បវស និងសំអាងលើការចង់រីក៏ប្រឈមមុខនិងឧបសគ្គពិតៗដ៏ច្រើន។ សំនួរដ៏ទូលំទូលាយសំរាប់គណៀនីយភាពគឺគួតែក្រុមភ្នាក់ងារយុទ្ធសាស្ត្រទាំងនេះស្ថិតនៅឆ្ងាយពីប្រព័ន្ធដ៏ធំរបស់សេដាកនិងការដាំដុះស្រូវ បវស រឺទេ?

ខ្ញុំក៏បានធ្វើការសន្និដ្ឋានផងដែរថា ការបង្ខាប់បញ្ញារបស់អង្គការ សេដាក តំរូវឲ្យបុគ្គលិកត្រូវចូលរួមជានិច្ចក្នុងរាល់សកម្មភាពដែលដាក់ពួកគេឲ្យនៅឆ្ងាយពីក្រុមយុទ្ធសាស្ត្រ ហើយកំនត់នូវសមត្ថភាពរបស់ពួកគេដើម្បីឲ្យឃើញពីសកម្មភាពនៃឧបសគ្គទៅលើគណៀនីយភាព។ ការបង្ខាប់បញ្ញាដើម្បីធ្វើឲ្យប្រសើរឡើងនូវភូមិគោលដៅរបស់គេដើម្បីឲ្យសកម្មភាពរបស់អង្គការកាន់តែមានកំរិតខ្ពស់ទៅៗក្នុងការដោះស្រាយឲ្យពួកគេជៀសឆ្ងាយពីអ្នកភូមិដែលជំទាស់និងញញឹតញញើម។ បន្ថែមលើនេះទៀតមានការកើនឡើងនូវការទាមទារពីបុគ្គលិកដើម្បីធ្វើអោយការងារមានភាពចំរើនជឿនលឿនក្នុងតំណើរការគំរោង។ **ការប៉ាន់ប្រមាណពីផលប៉ះពាល់** ដែលកើតឡើងនូវការប្រកួតប្រជែងនិងការកើនឡើងនូវការត្រួតត្រាតាមរយៈការឃ្លាំមើលកសិករ។ ក្នុងគំរោងធ្វើជំនួញបុគ្គលិកមានការរវល់ខ្លាំងជាមួយនឹងតំរូវការរបស់សេដាក ដែលលទ្ធភាពរបស់ពួកគេមានការថយចុះ ក្នុងការបង្ហាញពីផលប្រយោជន៍ពិតរបស់គ្រួសារកសិករ។ ការទទួលយកកម្មវិធីអភិវឌ្ឍ និងសកម្មភាពស្រាជ្រាវ ជាសកម្មភាពលេចធ្លោរបស់ សេដាក សំរាប់ការពង្រីកនូវការបង្កើតកម្មវិធីកសិកម្មថ្មីដូចជា បវស ទៅក្នុងមនុស្សថ្មីៗទៀតដែលត្រូវបានជំនួសដោយការអនុវត្តន៍ជាចាំបាច់នៃគំរោងការធ្វើជំនួញ។

បន្ថែមលើទិសដៅរួមឆ្ពោះទៅនិរន្តភាពទីផ្សារនិងគំរូក្នុងការដើរតួជាអ្នកសំដែងសំរាប់ការអភិវឌ្ឍន៍ដោយចេរភាពបានបង្ហាញនូវហានិភ័យនិងឱកាសជាច្រើនសំរាប់អង្គការដូចជា សេដាក។ សេដាក បានបង្ហាញរួចហើយពីសមត្ថភាពពិសេសដើម្បីទទួលជោគជ័យជាមួយក្រុបខណ្ឌនៃការដើរតួជាអ្នកសំដែងថ្មីដូចជាការកើតឡើងនូវការលក់ផលិតផលសរីរា

[14] (Yi, 21 September 2007)

ង្គ ការកើនឡើងនូវក្រុមល្បាតសហគ្រិននៃគ្រួសារកសិករនិងការគាំទ្រពីរដ្ឋាភិបាលពីគំនិតផ្តួចផ្តើមនៃទីផ្សារ។ ប៉ុន្តែជោគជ័យទាំងនេះក៏ត្រូវបាននាំមកនូវការដូរទិញដ៏សំខាន់ក្នុងគណ្យនីយភាពរបស់ខ្លួននិងការធ្លាក់ចុះសមត្ថភាពសំរាប់សំអាងលើឯកសារបទពិសោធនៃអ្នកចូលរួមបច្ចុប្បន្នរបស់ខ្លួននិងដើម្បីដោះស្រាយនូវឧបសគ្គរបស់អ្នកចូលរួមដ៏មានសក្តានុពលរបស់ខ្លួន។ ការដាក់បង្ហាញត្រួសៗនេះបានកំនត់នូវកំរិតជីវភាពជនបទនិងការកាត់បន្ថយភាពក្រីក្រដែលអាចទទួលខុសត្រូវដើម្បីបញ្ជាក់ជាមួយនិរន្តភាពទីផ្សារដែលពឹងលើសកម្មភាពអភិវឌ្ឍន៍។

# ឯកសារយោង


Adams, W. M. (1990) *Green Development: Environment and Sustainability in the Third World*. London: Routledge.

Adams, W. M. (1995) 'Green Development Theory? Environmentalism and Sustainable Development' in J. Crush (Ed.), *Power of Development* (pp. 87-100). London: Routledge.

Aseniero, G. (1985) 'A Reflection on Developmentalism: From Development to Transformation' in *Development as Social Transformation* (pp. 48-85). Tokyo: United Nations University.

Bakewell, O. (2007). Keeping Them in Their Place: the ambivalent relationship between development and migration in Africa. International Migration Institute.

Callon, M. (1986a) 'The Sociology of an Actor-Network: The Case of the Electric Vehicle' in M. Callon, J. Law & A. Rip (Eds.), *Mapping the Dynamics of Science and Technology* (pp. 19-34). London: Macmillan.

Callon, M. (1986b) 'Some Elements of a Sociology of Translation: Domestication of the Scallops and the Fishermen of St Brieuc Bay' in J. Law (Ed.), *Power, Action and Belief: A New Sociology of Knowledge*. London: Routledge.

CEDAC. (2007). *CEDAC's Contribution to Agriculture and Rural Development in Cambodia*. Phnom Penh: Centre d'Étude et de Développement Agricole Cambodgien.

CEDAC. (2008). *CEDAC in Brief*. Phnom Penh, Cambodia: Centre d'Étude et de Développement Agricole Cambodgien.

Desai, B. (2006) 'Inside Out: Rationalizing Practices and Representations in Agricultural Development Projects' in D. Lewis & D. Mosse (Eds.), *Development Brokers and Translators: The Ethnography of Aid and Agencies* (pp. 173-193). Bloomfield, Connecticut: Kumarian Press.

Dobermann, A. (2004) 'A critical assessment of the system of rice intensification (SRI)', *Agricultural Systems, 79*(3): 261-281.

Freeman, A. M. I. (1998) 'The Ethical Basis of the Economic View of the Environment' in D. VanDeVeer & C. Pierce (Eds.), *The Environmental Ethics and Policy Book* (pp. 293-301). Belmont, CA: Wadsworth Publishing.

Friberg, M., & Hettne, B. (1985) 'Greening of the World - Towards a Non-Deterministic Model of Global Processes' in *Development as Social Transformation* (pp. 204-270). Tokyo: United Nations University.

Haque, M. S. (1999) 'The Fate of Sustainable Development Under Neo-Liberal Regimes in Developing Countries', *International Political Science Review, 20*(2): 197-218.

Jacobs, M. (1999) 'Sustainable Development as a Contested Concept' in A. Dobson (Ed.), *Fairness and Futurity: Essays on Environmental Sustainability and Social Justice* (pp. 21-45). Oxford: Oxford University Press.

Kingdom of Cambodia. (2000). *National Report on the Implementation of the Convention to Combat Desertification*. Phnom Penh, Cambodia.

Knorr-Cetina, K. (1981) 'The micro-sociological challenge of macro-sociology: towards a reconstruction of social theory and methodology' in K. D. Knorr & A. Cicourel (Eds.), *Advances in social theory and methodology: toward an integration of micro- and macro-sociologies* (pp. 1-47). Boston: Routledge.

Latour, B. (1987) *Science in Action: How to Follow Scientists and Engineers Through Society*. Milton Keynes: Open University Press.

Laulanié, H. d. (1993) 'Le système de riziculture intensive malgache', *Tropicultura, 11*: 110-114.

Leopold, A. (1981) 'The Land Ethic' in *A Sand County Almanac* (pp. 237-265). Oxford: Oxford University Press.

McDonald, A. J., Hobbs, P. R., & Riha, S. J. (2006) 'Does the system of rice intensification outperform conventional best management?: A synopsis of the empirical record', *Field Crops Research, 96*(1): 31-36.

Moser, C. M., & Barrett, C. B. (2003) 'The disappointing adoption dynamics of a yield-increasing, low external-input technology: the case of SRI in Madagascar', *Agricultural Systems, 76*(3): 1085-1100.

Rajpal, P. (2008). *The Adoption and Disadotion Behaviour of SRI Farmers in Cambodia.* Waltham, Massachusettes: Heller School for Social Policy and Management, Brandeis University.

Satyanarayana, A., Thiyagarajan, T. M., & Uphoff, N. (2007) 'Opportunities for water saving with higher yield from the system of rice intensification', *Irrigation Science, 25*: 99-115.

Sheehy, J. E., Peng, S., Dobermann, A., Mitchell, P. L., Ferrer, A., Yang, J., et al. (2004) 'Fantastic yields in the system of rice intensification: fact or fallacy?' *Field Crops Research, 88*: 1-8.

Sheehy, J. E., Sinclair, T. R., & Cassman, K. G. (2005) 'Curiosities, nonsense, non-science and SRI', *Field Crops Research, 91*(355-356).

Singer, P. (1974) 'All Animals Are Equal', *Philosophical Exchange, I*: 103-116.

Stoop, W. A., Uphoff, N., & Kassam, A. (2002) 'A review of agricultural research issues raised by the system of rice intensification (SRI) from Madagascar: opportunities for improving farming systems for resource-poor farmers', *Agricultural Systems, 71*: 249-274.

Suon, S. (2007a). *Impact of CEDAC Development Program on Small Famers' Livelihood*. Phnom Penh, Cambodia: Centre d'Étude et de Développement Agricole Cambodgien.

Suon, S. (2007b). *Sustainable Rice-Based Livelihoods for Small Farmers in Takeo and Kampong Speu, Cambodia*. Phnom Penh, Cambodia: Centre d'Étude et de Développement Agricole Cambodgien.

SustainAbility. (2003). *The 21st Century NGO: In the Market for Change*. London, New York and Paris: SustainAbility, the UN Global Compact, United Nations Environment Programme.

Uphoff, N. (2003) 'Higher Yields with Fewer External Inputs? The System of Rice Intensification and Potential Contributions to Agricultural Sustainability', *International Journal of Agricultural Sustainability, 1*(1): 38-50.

Uphoff, N. (2005) 'The development of the System of Rice Intensification' in J. Gonsalves, T. Becker, A. Braun, D. Campilan, H. de Chavez, E. Fajber, M. Kapiriri, J. Rivaca-Caminade & R. Vernooy (Eds.), *Participatory Research and Development for Sustainable Agriculture and Natural Resource Management: A Sourcebook* (Vol. 3, pp. 119-125). Ottawa: International Potato Center-UPWARD and International Development Research Centre.

Uphoff, N. (2006a). Comments on Data an Data Sources for Table 1 in McDonald et al. (2006). Cornell International Institute for Food, Agriculture, and Development.

Uphoff, N. (2006b). Increasing Water Savings While Raising Yields with the System of Rice Intensification (SRI). Cornell International Institute for Food, Agriculture and Development.

White, L. (1967) 'The Historical Roots of Our Ecological Crisis', *Science, 155*: 1203-1207.

Wilson, E. O. (1996) 'Biophilia and the Environmental Ethic' in *In Search of Nature* (pp. 165-179). Washington, D.C.: Island Press.

Wright, S. (1994) 'Introduction to Part III - Clients and Empowerment' in S. Wright (Ed.), *Anthropology of Organizations* (pp. 161-167). London: Routledge.

Yang Saing, K. (1 August). *Personal communication*. Phnom Penh

Yi, K. (21 September). *Personal communication*. Angtasaom, Cambodia